# បេឡាជាតិរបបសន្តិសុខសង្គម
# National Social Security Fund

ព្រឹត្តិបត្រព័ត៌មាន

ប.ស.ស ឆ្នាំទី០៨ លេខ២២ ឆ្នាំ២០១៨




ទំនាក់ទំនងបន្ទាន់

២៤ម៉ោង/៧ថ្ងៃ

១២៨៦

- ធានាសន្តិសុខប្រាក់ចំណូល
- រួមចំណែកកាត់បន្ថយភាពក្រីក្រ
- លើកកម្ពស់ស្ថិរភាពសង្គម


សួស្តីឆ្នាំថ្មី
ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦២ គ្រិស្តសករាជ ២០១៨
មហាសករាជ ១៩៤០ ចុល្លសករាជ ១៣៨០
អបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ
សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងទេវតាឆ្នាំថ្មី ព្រះនាម មហោធរៈទេវី ប្រសិទ្ធិពរជ័យដល់
ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក កម្មករ កម្មការិនី ព្រមទាំងបងប្អូនប្រជាជនខ្មែរទូទាំងប្រទេស
ជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។


បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)
National Social Security Fund ( N S S F )
សួស្តីឆ្នាំថ្មី
ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦២ គ្រិស្តសករាជ ២០១៨
មហាសករាជ ១៩៤០ ចុល្លសករាជ ១៣៨០
អបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ
សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងទេវតាឆ្នាំថ្មី ព្រះនាម មហោធរៈទេវី ប្រសិទ្ធិពរជ័យដល់
ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក កម្មករ កម្មការិនី ព្រមទាំងបងប្អូនប្រជាជនខ្មែរទូទាំងប្រទេស
ជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។
ធានាសន្តិសុខប្រាក់ចំណូល រួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកម្ពស់សុខុមាលភាពសង្គម
បេឡាជាតិរបបសន្តិសុខសង្គម - ប.ស.ស
www.nssf.gov.kh
info@nssf.gov.kh



# មាតិកាព្រឹត្តិបត្រព័ត៌មាន ប.ស.ស


| ល.រ | ខ្លឹមសារអត្ថបទ | ទំព័រ |
|---|---|---|
| ០១ | សម្តេចតេជោ ផ្តល់អនុសាសន៍ ០៩ចំណុច ដើម្បីលើកកម្ពស់ជីវភាពរបស់កម្មករនិយោជិត | ០១ |
| ០២ | ប្រទេសកូរ៉េផ្តល់កូតាជាង៤ពាន់នាក់លើវិស័យឧស្សាហកម្ម.. | ០៣ |
| ០៣ | ប្រទេសកាណាដានៅតែបន្តបញ្ជាទិញសម្លៀកបំពាក់ពីប្រទេសកម្ពុជា | ០៤ |
| ០៤ | កម្មវិធីប្រឡងសម្រស់ឯកវាយនភណ្ឌ តំបន់7NG | ០៥ |
| ០៥ | បេឡាជាតិរបបសន្តិសុខសង្គម បានចុះអនុស្សារណៈយោគយល់គ្នាជាមួយសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ | ០៧ |
| ០៦ | ប.ស.ស បានចុះអនុស្សារណៈយោគយល់ ស.ស.យ.ក ដើម្បីពង្រឹងសុវត្ថិភាពធ្វើដំណើររបស់បងប្អូនកម្មករនិយោជិត | ០៩ |
| ០៧ | ពិធីប្រជុំបូកសរុបសមិទ្ធផល រយៈពេល១០ឆ្នាំ និងទិសដៅការងារឆ្នាំ២០១៨ របស់បេឡាជាតិរបបសន្តិសុខសង្គម | ១១ |
| ០៨ | ប.ស.ស ផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាលជូនប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ នៅសាលាស្រុកស្វាយអន្ទរ | ១៤ |
| ០៩ | កិច្ចប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម នៅខេត្តប៉ៃលិន | ១៥ |
| ១០ | បេឡាជាតិរបបសន្តិសុខសង្គម ផ្តល់បណ្ណសមាជិក ដល់បុគ្គលិកប៉ៃលិនធី ចំនួន ៥១៨នាក់ | ១៧ |
| ១១ | កិច្ចប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គមនៅខេត្តកំពង់ធំ | ១៩ |
| ១២ | ពិធីប្រគល់បណ្ណមូលនិធិសមធម៌សុខាភិបាល និងបណ្ណចេញ-ចូលបរិវេណតំបន់សេដ្ឋកិច្ចពិសេស នៅខេត្តព្រះសីហនុ | ២០ |
| ១៣ | ពិធីប្រគល់បណ្ណមូលនិធិសមធម៌សុខាភិបាល និងបណ្ណសម្គាល់យានយន្តដល់អ្នកបើកបរដឹកកម្មករ | ២១ |








| | | |
|---|---|---|
| ១៤ | ពិធីផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាលប្រធានភូមិ អនុ-ប្រធានភូមិ សមាជិកភូមិ នៅសាលាស្រុកក្រូចឆ្មារ | ២៥ |
| ១៥ | សកម្មភាពក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកផ្សព្វផ្សាយច្បាប់ចរាចរណ៍ និងផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល | ២៦ |
| ១៦ | សកម្មភាព បេឡាជាតិរបបសន្តិសុខសង្គម ចុះកំណត់អត្តសញ្ញាណកម្មករនិយោជិត | ២៨ |
| ១៧ | ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ ចុះអង្កេតករណីសន្លប់នៅខេត្តកំពង់ស្ពឺ | ២៩ |
| ១៨ | បុគ្គលិកគ្រឹះស្ថានប្រាសាក់ម្នាក់ទទួលបានថ្លៃសេវាព្យាបាលពីបេឡាជាតិរបបសន្តិសុខសង្គម | ៣០ |
| ១៩ | ប.ស.ស ចេញថ្លៃសេវាព្យាបាលរហូតជាសះស្បើយលើកម្មករកម្មការិនី ៦៣នាក់ នៅខេត្តព្រះសីហនុ | ៣០ |
| ២០ | ប.ស.ស បានផ្តល់ប្រាក់វិភាជន៍បូជាសពដល់កម្មការិនីម្នាក់ដែលបានស្លាប់ដោយសារខ្យល់គរនៅខេត្តស្វាយរៀង | ៣១ |
| ២១ | នីតិវិធី ដើម្បីទទួលបានបណ្ណសមាជិក ប.ស.ស | ៣២ |
| ២២ | តើអ្នកណាខ្លះដែលអាចប្រើប្រាស់បណ្ណសមាជិក ប.ស.ស | ៣២ |
| ២៣ | បណ្ណសមាជិក ប.ស.ស និងបណ្ណមូលនិធិសមធម៌សុខាភិបាល | ៣៣ |
| ២៤ | ធនាគារដែលនិយោជកអាចបង់ភាគទានមកកាន់ ប.ស.ស | ៣៣ |
| ២៥ | សុភាសិតរបស់សម្តេចព្រះមហាសុមេធាធិបតី ជួន ណាត (ជោតញ្ញាណោ) សម្តេចព្រះសង្ឃរាជថ្នាក់ទី១ | ៣៤ |
| ២៦ | រាជរដ្ឋាភិបាលសម្រេចដាក់ឱ្យប្រើប្រាស់ក្រដាសប្រាក់ ២០ ០០០រៀល គំរូប្រភេទថ្មី | ៣៥ |
| ២៧ | វិធីសាស្ត្រងាយៗកំចាត់ជំងឺផ្តាសាយ | ៣៥ |
| ២៨ | តើមានអ្វីកើតឡើងក្រោយពីអ្នកឈប់ជក់បារីរយៈពេល២១ថ្ងៃ | ៣៦ |
| ២៩ | <u>កំណាព្យៈ</u> ក្រមា១ពាន់ម៉ែត្រ បានព្រោះហេតុខ្មែររួមគ្នា | ៣៧ |










# រចនាសម្ព័ន្ធព្រឹត្តិបត្រ

## ឯកឧត្តម អ៊ុក សមវិទ្យា
## នាយក ប.ស.ស

| | |
|---|---|
| **ចាងហ្វាង** | ឯកឧត្តម **ជាវ ប៊ុនរិទ្ធ** |
| **និពន្ធនាយក** | លោក **ហែម សុគន្ធារិន** |
| **និពន្ធនាយករង** | លោក **នៅ សុមនា** |
| **លេខានិពន្ធ** | លោក **នាង ជូ** |
| | លោក **យន គន្ធា** |
| | លោក **លីម តក់** |
| **ផ្នែកការីកុំព្យូទ័រ** | លោក **ពៅ សុវណ្ណារ៉ា** |
| | លោក **យង់ សុខន** |
| | លោក **ប៊ុត ស៊ឹម** |

# អង្គការលេខរបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន
មន្ទីរព័ត៌មានរាជធានីភ្នំពេញ
លេខ..៣៣៦../ស.ពមរ/១៧

ភ្នំពេញ,ថ្ងៃទី..០៦..ខែ..ធ្នូ........ឆ្នាំ២០១៧

## លិខិតអនុញ្ញាត

## ប្រធានមន្ទីរព័ត៌មានរាជធានីភ្នំពេញ

យោង: -ប្រកាសលេខ១០៨ព.ម.ប្រ.ក ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៤ របស់ក្រសួងព័ត៌មាន។

-លិខិតអនុញ្ញាតលេខ០០៤/១៧ល.អ.ព.ម.រ ចុះថ្ងៃទី ០៣ ខែមករា ឆ្នាំ ២០១៧ របស់មន្ទីរព័ត៌មានរាជធានីភ្នំពេញ។

-ពាក្យស្នើសុំអនុញ្ញាតបន្តអាជ្ញាប័ណ្ណបោះពុម្ពផ្សាយព្រឹត្តិបត្រ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៧ របស់លោក ជាវ ប៊ុនរិទ្ធ ចាងហ្វាងការផ្សាយព្រឹត្តិបត្រ បេឡាជាតិរបបសន្តិសុខសង្គម។

តាមសេចក្តីយោងខាងលើនេះ មន្ទីរព័ត៌មានរាជធានីភ្នំពេញ សូមជម្រាបជូនមកលោក ជាវ ប៊ុនរិទ្ធ ចាងហ្វាងការផ្សាយព្រឹត្តិបត្រ បេឡាជាតិរបបសន្តិសុខសង្គម ជ្រាបថា មន្ទីរព័ត៌មានរាជធានីភ្នំពេញ អនុញ្ញាតឲ្យលោកចាងហ្វាងបន្តដំណើរការបោះពុម្ពផ្សាយចាងហ្វាងការផ្សាយព្រឹត្តិបត្រ បេឡាជាតិរបបសន្តិសុខសង្គម ដែលមានទីស្នាក់ការនៅអាគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ បន្តពីលិខិតអនុញ្ញាតលេខ០០៤/១៧ ល.អ.ព.ម.រ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧ របស់មន្ទីរព័ត៌មានរាជធានីភ្នំពេញ។

ក្នុងដំណើរការបោះពុម្ពផ្សាយ លោកចាងហ្វាងត្រូវគោរពអនុវត្តឲ្យបានត្រឹមត្រូវតាមខ្លឹមសារប្រកាសរបស់ក្រសួងព័ត៌មាន ដូចយោងខាងលើ។

ករណីប្រព្រឹត្តល្មើស នឹងប្រកាសអនុញ្ញាតរបស់ក្រសួងព័ត៌មាន សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន។

លិខិតអនុញ្ញាតនេះ មានសុពលភាពរយៈពេល ០១ (មួយឆ្នាំ) គិតពីថ្ងៃចុះហត្ថលេខាតទៅ។

ប្រធានមន្ទីរ

ឃុត_សំខាន់

***កន្លែងទទួល***
-ក្រសួងព័ត៌មាន
-អគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍
-សាលារាជធានីភ្នំពេញ
(ដើម្បីជ្រាបជាព័ត៌មាន)
-កងរាជអាវុធហត្ថរាជធានីភ្នំពេញ
-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
-ឯកសារ-កាលប្បវត្តិ

អាស័យដ្ឋាន : លេខ២, មហាវិថីសហព័ន្ធរុស្ស៊ី, សង្កាត់មនោរម្យ, ខណ្ឌ៧មករា ។
Website: www.midphnompenh.com / E-mail: Midphnompenh@gmail.com

# សម្តេចតេជោ ផ្តល់អនុសាសន៍ ០៩ចំណុច ដើម្បីលើកកម្ពស់ជីវភាពរបស់កម្មករនិយោជិត



ព្រះសីហនុ៖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃអាទិត្យ ៣រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៨ បានអញ្ជើញជួបសំណេះសំណាលជាមួយ កម្មករកម្មការិនី ចំនួន ១៤ ០២៥នាក់ មកពីរោងចក្រចំនួន១៤ ស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេស ខេត្តព្រះ-សីហនុ។



កម្មករនិយោជិតចូលរួមក្នុងពិធីសំណេះសំណាល

រោងចក្រសហគ្រាសទាំង១៤ ដែលមានកម្មករនិយោជិតមកជួបសំណេះសំណាល ជាមួយ **សម្តេចតេជោ** នេះ មានអ្នកវិនិយោគមកពីប្រទេសចិនចំនួន ០៧ សហគ្រាស បារាំង



កម្មករនិយោជិតចូលរួមក្នុងពិធីសំណេះសំណាល

០១ សហគ្រាស ជប៉ុនចំនួន ០២ សហគ្រាស សហរដ្ឋអាមេរិកចំនួន ០៣ សហគ្រាស និងកំពង់ផែស្វយ័តក្រុងព្រះសីហនុផងដែរ ពិធីសំណេះសំណាលនេះមានគោលបំណងស្វែងយល់ពីសុខទុក្ខរបស់បងប្អូនកម្មករនិយោជិត និងដើម្បីដោះស្រាយបញ្ហា ប្រឈមនានាមួយចំនួនរបស់កម្មករព្រមទាំងជម្រុញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មពីឆ្នាំ (២០១៥-២០២៥) ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ដើម្បីពង្រឹងសេដ្ឋកិច្ចជាតិ និងលើកកម្ពស់ជីវភាពរបស់ពលរដ្ឋឱ្យកាន់តែល្អប្រសើរ។

នៅក្នុងឱកាសនោះ **សម្តេចតេជោ** បានដាក់ចេញនូវសារសំខាន់ៗចំនួន **០៩ចំណុច** រួមមាន៖


សម្តេចតេជោ សំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត

១. អនុវត្តន៍ប្រាក់ខែអប្បបរមា **១៧០ដុល្លារ** ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨នេះតទៅ។

២. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាលត្រូវអនុវត្តការចុះពិនិត្យ ការព្យាបាលជំងឺដោយមិនបង់ប្រាក់នៅតាមមន្ទីរពេទ្យរដ្ឋ ដល់កម្មករ-កម្មការិនីទាំងក្នុង និងក្រៅប្រព័ន្ធតាមរយៈមូលនិធិសមធម៌សុខាភិបាលរួមទាំងកីឡាករ កីឡាការិនី ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ និងក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវអនុវត្តឱ្យបានម៉ត់ចត់។

៣. អនុវត្តន៍ការផ្តល់ជូនថវិកាដល់កម្មការិនីសម្រាលកូន នឹងទទួលបានការឈប់សម្រាកពីការងារចំនួន ៩០ថ្ងៃ ហើយទទួលបានប្រាក់ឈ្នួល ១២០% (៥០% ផ្តល់ដោយនិយោជក និង ៧០% ទៀតផ្តល់ដោយ ប.ស.ស) ក្រសួងពាក់ព័ន្ធត្រូវតាមដានការងារឱ្យដិតដល់ចំពោះការអនុវត្តសកម្មភាពនេះ។

៤. អនុវត្តន៍ការឧបត្ថម្ភថវិកាជូនដល់កម្មការិនីសម្រាលកូន ០១នាក់ ទទួលបានថវិកា ៤០០ ០០០រៀល សម្រាលបានកូនភ្លោះ ០២នាក់ ទទួលបានថវិកា ៨០០ ០០០រៀល សម្រាលបានកូនភ្លោះ ០៣នាក់ ទទួលបានថវិកា ១ ២០០ ០០០រៀល រួមទាំងថវិកាឧបត្ថម្ភចំនួន ៥ ០០០ ០០០រៀល បន្ថែមទៀត


សម្តេចតេជោ ចុះសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិតដោយផ្ទាល់

ពី **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** និងការពិនិត្យផ្ទៃពោះដោយឥតគិតថ្លៃផងដែរ បើទោះបីជាសម្រាលកូនមកស្លាប់ក៏ដោយ ក៏ទទួលបានដូចគ្នា។

៥. អនុវត្តន៍របបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១៨ កម្មករ កម្មការិនី មិនជាប់កាតព្វកិច្ចបង់ភាគទានទេ គឺនិយោជកជាអ្នកបង់ជំនួស១០០%។

៦. អនុវត្តន៍តាមដានលើបញ្ហាទឹក អគ្គិសនី ហើយចំពោះកម្មករ កម្មការិនីដែលមិនទាន់មាន ទឹក អគ្គិសនី ប្រើប្រាស់ដែលនៅតំបន់ឆ្ងាយ ត្រូវរៀបចំតបណ្តាញទឹកអគ្គិសនីឱ្យបានឆាប់រហ័ស រួមទាំងស្នើកុំឱ្យតម្លៃផ្ទះជួលឡើងថ្លៃសម្រាប់ឆ្នាំ២០១៨នេះ។

៧. អនុវត្តន៍ប្រាក់សោធននិវត្តន៍ ចាប់ពីឆ្នាំ២០១៩ ជូនដល់កម្មករ កម្មការិនី ដូច្នេះក្នុងរយៈពេលពេញ ០១ឆ្នាំ ២០១៨នេះ ត្រូវរៀបចំឱ្យរួចរាល់ដើម្បីដំណើរការឱ្យបានល្អនូវរបបសោធននិវត្តន៍នេះ។


សម្តេចតេជោ ចុះសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិតដោយផ្ទាល់

៨. អនុវត្តន៍ការចូលរួមបន្តយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហាផ្សេងៗ ចំពោះពលករនៅក្រៅប្រទេស និងជួយសម្រួលបែបបទ លិខិតបទដ្ឋានផ្លូវច្បាប់នានា ដើម្បីទទួលបាននូវលក្ខខណ្ឌការងារល្អប្រសើរ។

៩. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចុះអនុវត្តតាមដានភ្លាមៗឱ្យបានដិតដល់ និងចូលរួមដោះស្រាយបញ្ហាប្រឈមនានាចំពោះកម្មករកម្មការិនី នៅពេលដែលម្ចាស់រោងចក្ររត់ចោល។ ក្នុងនោះ គឺត្រូវដោះស្រាយផ្តល់ប្រាក់ឈ្នួលជាបន្ទាន់ដល់កម្មករកម្មការិនីដែលកំពុងធ្វើការក្នុងពេលដែលថៅកែ រោងចក្របានរត់ចោល ហើយត្រូវបន្តដោះស្រាយបញ្ហានានា ជាមួយម្ចាស់រោងចក្រដោយផ្ទាល់។ ទន្ទឹមគ្នានោះដែរ គឺត្រូវជួយរកការងារធ្វើឱ្យកម្មករ កម្មការិនីឱ្យបានឆាប់រហ័សបំផុត ។

# ប្រទេសកូរ៉េ ផ្តល់កូតាជាង ៤ពាន់នាក់ លើវិស័យ ឧស្សាហកម្ម



ភ្នំពេញ៖ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃសុក្រ ១៥រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨ បានអនុញ្ញាតឱ្យ **ឯកឧត្តម** OHNAK YUONG ឯកអគ្គរដ្ឋទូតនៃសាធារណៈរដ្ឋកូរ៉េ ប្រចាំប្រទេសកម្ពុជា ចូលជួបពិភាក្សាការងារនៅទីស្តីការក្រសួង។ ជំនួបពិភាក្សាការងារនេះ ធ្វើឡើងក្នុងគោលបំណងលើកិច្ចសហប្រតិបត្តិការលើវិស័យការងារនិងការផ្តល់ឱកាសឱ្យបងប្អូនពលករកម្ពុជាទៅធ្វើការនៅសាធារណៈរដ្ឋកូរ៉េរួមទាំងសុវត្ថិភាពការងារដែលភាគីកូរ៉េតែងតែបានផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេសមកដល់ពេទ្យការងារ ក្នុងការអប់រំផ្សព្វផ្សាយអំពីប្រព័ន្ធអនាម័យសុវត្ថិភាពការងារ ការបណ្តុះបណ្តាលសមត្ថភាពបច្ចេកទេស និងការផ្តល់ឧបករណ៍បច្ចេកទេសសម្រាប់ការពិនិត្យស្ថានភាពការងារនៅតាមសហគ្រាសជាដើម។

**ឯកឧត្តម** ឯកអគ្គរដ្ឋទូតនៃសាធារណៈរដ្ឋកូរ៉េ បានមានប្រសាសន៍ថា ចំពោះប្រព័ន្ធអនុញ្ញាតនៃមុខរបរ Employment Permit System (EPS) នាពេលថ្មីៗនេះ ប្រទេសកូរ៉េបានផ្តល់ការអនុញ្ញាតឱ្យប្រទេសឡាវបញ្ជូនពលករទៅបម្រើការងារនៅប្រទេសកូរ៉េដែរ ប៉ុន្តែបញ្ហានេះគឺមិនប៉ះពាល់ដល់ចំនួនកូតារបស់កម្ពុជានោះឡើយ។

នៅក្នុងជំនួបពិភាក្សាការងារនេះដែរ **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** បានស្នើទៅភាគីកូរ៉េជួយបន្ថែមវិស័យសេវាកម្ម សម្រាប់ពលករទៅធ្វើការនៅប្រទេសកូរ៉េថែមលើវិស័យឧស្សាហកម្ម កសិកម្ម និងសំណង់ដែលមាននាពេលបច្ចុប្បន្ន។ **ឯកឧត្តម** ឯកអគ្គរដ្ឋទូតបានទទួលយកសំណើ ទាំងអស់នោះសិនដើម្បីយកទៅពិចារណា ខណៈដែលបច្ចុប្បន្នប្រទេសកូរ៉េនាពេលបច្ចុប្បន្នមិនទាន់បានគិតលើវិស័យនេះនៅឡើយទេ។



នៅកិច្ចបញ្ចប់នៃការពិភាក្សាការងារភាគីទាំងពីរបានសន្យាថានឹងបន្តពង្រីកកិច្ចសហប្រតិបត្តិការនេះថែមទៀតនាឆ្នាំបន្ទាប់។ ឆ្នាំ២០១៨ នេះប្រទេសកូរ៉េនឹងផ្តល់កូតាប្រមាណជាង ០៤ពាន់នាក់ លើវិស័យឧស្សាហកម្មដោយមិនរាប់បញ្ចូលលើវិស័យកសិកម្ម និងសំណង់នៅឡើយសម្រាប់ពលករទៅធ្វើការនៅប្រទេសកូរ៉េនាឆ្នាំនេះ គឺមានចំនួនប្រហាក់ប្រហែលនឹងឆ្នាំ២០១៧ដែរ ហើយប្រទេសកម្ពុជានៅតែទទួលបានចំណាត់ថ្នាក់ល្អ បើប្រៀបធៀបជាមួយនឹងបណ្តាប្រទេស១៦ ផ្សេងទៀត៕

# ប្រទេសកាណាដានៅតែបន្តបញ្ជាទិញសម្លៀកបំពាក់ពីប្រទេសកម្ពុជា



ភ្នំពេញ៖ នៅព្រឹកថ្ងៃសុក្រ ១៥រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨ នេះ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុញ្ញាតឱ្យ **លោកស្រី ដូនីកា ប៉ូតធី (DONICA POTTIE)** ឯកអគ្គរដ្ឋទូតកាណាដាប្រចាំនៅកម្ពុជា ចូលជួបពិភាក្សាការងារនៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ក្នុងជំនួបពិភាក្សាការងារនេះ លោកជំទាវឯកអគ្គរដ្ឋ-ទូត បានសន្យាថាប្រទេសកាណាដា នៅតែបន្តបញ្ជាទិញទំនិញផ្នែកវាយនភណ្ឌសម្លៀកបំពាក់ពីកម្ពុជាបន្ថែមទៀត ខណៈដែលប្រទេសនេះបានដកការបញ្ជាទិញពីបណ្តាប្រទេសពាក់ព័ន្ធមួយចំនួន ផ្សេងទៀត។

**ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** បានបញ្ជាក់ថា ពេលនេះ ប្រទេសកាណាដាបានដកការបញ្ជាទិញពីប្រទេសមួយចំនួន ប៉ុន្តែចំពោះប្រទេសកម្ពុជា ប្រទេសកាណាដានៅតែរក្សាដដែល មិនមានអ្វីប្រែប្រួលឡើយ។ **ឯកឧត្តមបណ្ឌិត** បានបន្តថា ដោយឡែកតម្លៃនៃការនាំចេញទៅកាន់ប្រទេសកាណាដា ក៏ស្ថិតក្នុងស្ថានភាពល្អប្រសើរដែរ ប្រទេសកាណាដាបានផ្តល់ភាពអនុគ្រោះសម្រាប់ការនាំចូល ដោយគិតមកទល់ពេលនេះមានចំនួន ទឹកប្រាក់ប្រមាណជាង ៩០លានដុល្លារអាមេរិក។ **ឯកឧត្តមបណ្ឌិត** បានបញ្ជាក់ថា កត្តាដែលភាគីកាណាដានៅតែបន្តបញ្ជាទិញ ដោយសាររាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយល្អ ក្នុងការដោះស្រាយលក្ខខណ្ឌការងារ ប្រាក់ឈ្នួលកើនឡើង និងធ្វើឱ្យមានការប្រកួតប្រជែង និងមានភាពអនុគ្រោះ ហើយដោយសារអ្នកប្រើប្រាស់ទំនិញនៅអឺរ៉ុបប្រទេសមួយចំនួនក៏ពេញចិត្តនូវលក្ខខណ្ឌដែលបានផ្តល់ជូនបងប្អូនកម្មករនិយោជិតផងដែរ ជាពិសេសចុងក្រោយនេះមានការគាំទ្រ គឺជាគោលនយោបាយគាំពារសង្គមរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចតេជោ** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់នូវអត្ថប្រយោជន៍ដល់បងប្អូន កម្មករនិយោជិត ជាពិសេសស្ត្រីដែលជម្រុញឱ្យមានការទាក់ទាញកាន់តែខ្លាំងទាំងអ្នកប្រើប្រាស់ និងអ្នកបញ្ជាទិញ។ កត្តាទាំងនេះហើយ ទើបធ្វើឱ្យអ្នកបញ្ជាទិញកាន់តែចាប់អារម្មណ៍ខ្លាំងឡើងថែមទៀតផង៕





# កម្មវិធីប្រឡងសម្រស់ឯកវាយនភណ្ឌ តំបន់7NG

**ភ្នំពេញ៖** កម្មវិធីប្រឡងសម្រស់ឯកវាយនភណ្ឌតំបន់ 7NGដោយមានការសហការជាមួយក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ ធ្វើឡើងនៅថ្ងៃពុធ ៦រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨។ ក្នុងវគ្គផ្តាច់ព្រ័ត្រនេះមានបេក្ខនារីចំនួន ១២នាក់ និងបេក្ខជនចំនួន ១២នាក់ បានចូលរួមប្រកួតប្រជែងដណ្តើមជ័យលាភីលេខ១ ដល់លេខ៣ ក្រោមអធិបតីភាពរបស់ **លោកជំទាវ ខួន សុខា** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាតំណាងរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **ឯកឧត្តម ហេង សួរ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង **លោកឧកញ៉ា ស្រី ចាន់ថន** អគ្គនាយកក្រុមហ៊ុន ជេតស៍ គ្រុប 7NG-Sky Land។



**លោកជំទាវ ខួន សុខា** មានប្រសាសន៍ថា ក្រោមគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្រុមការងារបានរៀបចំកម្មវិធីប្រឡងសម្រស់វាយនភណ្ឌតំបន់ 7NG នេះឡើងក្នុងគោលបំណងលើកកម្ពស់តម្លៃការងារកម្មករកម្មការិនី ដែលបម្រើការងារ ផ្នែកវាយនភណ្ឌ វិស័យកាត់ដេរ ផលិតស្បែកជើង និងវិស័យសេដ្ឋកិច្ចផ្សេងៗទៀត ព្រមទាំងចូលរួមអបអរសាទរខួបអនុស្សាវរីយ៍លើកទី១០៧ ទិវាអន្តរជាតិនារី ៨ មីនា ផងដែរ។



ក្នុងឱកាស ទិវាអន្តរជាតិនារី ៨ មីនា នេះ **លោកជំទាវ** បានលើកឡើងថា បើគ្មានស្ត្រីទេ បុរសមិនអាចសម្រេចកិច្ចការងារបានគ្រប់យ៉ាងនោះទេ លុះត្រាតែមានការចូលរួមពីភាគីស្ត្រីក្នុងការសម្រេចចិត្តធ្វើអ្វីមួយ ដូចពាក្យចាស់បុរាណតែងលើកឡើងថា "សំណាបយោងដីស្រីយោងបុរស" ឬ "សម្លឆ្ងាញ់ដោយសារគ្រឿង គ្រួសាររុងរឿងដោយសារភរិយា"។

ការប្រកួតសម្រស់ឯកវាយនភណ្ឌ 7NG នេះ ជ័យលាភីលេខ០១ បានទៅលើបេក្ខនារី **នី ស្រីពេជ្រ** មកពីរោងចក្រ KYUNG SHIN CAMBODIA CORP ជ័យលាភីលេខ០២ បានទៅលើបេក្ខនារី **ម៉ៅ ធីតា** មកពីរោងចក្រតណ្ហចិន និងជ័យលាភីលេខ០៣ បានទៅលើបេក្ខនារី **ខន ពិសី** មកពីរោងចក្រតណ្ហចិន ចំណែកឯជ័យលាភីផ្នែកបុរស ជ័យលាភីលេខ០១ បានទៅលើបេក្ខជន **ឡុន ម៉េងលាង** មកពីរោងចក្រ CRYSTAL MATIN ជ័យលាភីលេខ០២ បានទៅបេក្ខជន **គង់ វីតាក់** មកពីរោងចក្រ KYUNGSHIN CAMBODIA និងជ័យលាភីលេខ០៣ បានទៅលើបេក្ខជន **លាង ស៊ីណា** មកពីរោងចក្រ CRYSTAL MATIN។











ចំពោះជ័យលាភី លេខ០១ ទទួលបាន ទឹកប្រាក់ចំនួន ២ ០០០ ០០០ រៀល ជ័យលាភី លេខ០២ ទទួលបានទឹកប្រាក់ចំនួន ១ ៥០០ ០០០ រៀល និងជ័យលាភី លេខ០៣ ទទួលបានទឹកប្រាក់ចំនួន ១ 000 000 រៀល ចំណែកឯអ្នកមិនជាប់ជ័យលាភីម្នាក់ៗទទួលបានទឹកប្រាក់ ២០០ ០០០ រៀល ផងដែរ។

# បេឡាជាតិរបបសន្តិសុខសង្គម បានចុះអនុស្សារណៈយោគយល់គ្នាជាមួយ សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ

ភ្នំពេញ៖ **បេឡាជាតិរបបសន្តិសុខសង្គម** (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃពុធ ១១រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨ បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាមួយ **សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ** (ស.គ.យ.ត) ដើម្បីពង្រឹង និងពង្រីកការផ្តល់សេវាសុខាភិបាលជូនដល់សមាជិក ប.ស.ស ដែលប្រារព្ធនៅសណ្ឋាគារភ្នំពេញ។



ពិធីនេះបានរៀបចំឡើងក្រោមអធិបតីភាព **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស និង **ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត** ប្រធានក្រុមប្រឹក្សាភិបាលសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ



ព្រមទាំងមានការអញ្ជើញចូលរួមពីសមាជិក សមាជិកា ប្រមាណជាង៥០ នាក់។

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** មានប្រសាសន៍ថា គោលបំណងនៃពិធីចុះអនុស្សារណៈយោគយល់នាពេលនេះគឺដើម្បីសម្រេចឱ្យបាននូវអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការពង្រឹង និងពង្រីកការផ្តល់សេវាសុខាភិបាលជូនដល់សមាជិក ប.ស.ស ឱ្យកាន់តែល្អប្រសើរឡើងដែលធ្វើឱ្យសមាជិក ប.ស.ស ទាំងអស់មានភាពងាយស្រួល និងកក់ក្តៅក្នុងការទទួលសេវាសុខាភិបាលតាមរយៈការសហការគ្នារវាង ប.ស.ស និង ស.គ.យ.ត ដែលពោរពេញទៅដោយវេជ្ជបណ្ឌិតជំនាញៗ និងមានបទពិសោធន៍ខ្ពស់ក្នុងការពិនិត្យ និងព្យាបាលជំងឺ។



ជាមួយគ្នានេះដែរ **ឯកឧត្តមបណ្ឌិតប្រធាន ក្រុមប្រឹក្សាភិបាល ស.គ.យ.ត** បានសម្តែងនូវអំណរសាទរយ៉ាងក្លៀវក្លា ដែលសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ បានសហការជាមួយ ប.ស.ស ក្នុងការរួមចំណែកផ្តល់សេវាព្យាបាលជូនបងប្អូនកម្មករនិយោជិត។

**ឯកឧត្តមបណ្ឌិត** បានបន្តថា កាលពីពេលកន្លងទៅ សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ បានសហការជាមួយក្រុមការងារ ប.ស.ស ក្នុងការចុះផ្តល់សេវាព្យាបាលដោយឥតគិតថ្លៃជូនដល់បងប្អូនកម្មករនិយោជិតក៏ដូចជាប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ និងបណ្តាខេត្តនានាផងដែរ។

សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ បានផ្តល់សេវាពិនិត្យ និងព្យាបាលជំងឺជូនបងប្អូនប្រជាពលរដ្ឋរួមមាន៖ ជំងឺទូទៅ ជំងឺមាត់ធ្មេញ វះកាត់តូច ភ្នែក ត្រចៀក ច្រមុះ បំពង់ក បេះដូង អេកូបេះដូង ឬសដូងបាត រោគស្ត្រី ពកក ថ្លើម សួត ក្រពះពោះវៀន សើស្បែក និងជំងឺអេកូស្ត្រីមានផ្ទៃពោះ និងពិនិត្យឈាមរកមេរោគផ្សេងៗទៀត។

សូមបញ្ជាក់ផងដែរថា **ស.គ.យ.ត** បង្កើតឡើងក្នុងគោលបំណងចំនួន ៣ធំៗ រួមមាន៖

១. ចូលរួមចំណែកជាមួយស្ថាប័នជាតិ ជាពិសេសក្រសួងសុខាភិបាល ដើម្បីផ្តល់សុខភាពសាធារណៈជូនបងប្អូន ប្រជាពលរដ្ឋដោយឥតគិតថ្លៃ និងមិនប្រកាន់ជាតិសាសន៍ ពណ៌សម្បុរ ឬនិន្នាការនយោបាយឡើយ។

២. ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈសកម្មភាពផ្តល់សេវាសុខភាពជូនប្រជាពលរដ្ឋក្រីក្រដល់ទីកន្លែង ជាពិសេសតាមទីជនបទដាច់ស្រយាលនានា។

៣. ចូលរួមចំណែកបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យសុខាភិបាល ក៏ដូចជាការផ្តល់ឱកាសដល់ប្អូនៗនិស្សិត និងយុវជនស្ម័គ្រចិត្តដទៃទៀត ឱ្យបានចូលរួមចំណែកបម្រើការងារមនុស្សធម៌ដល់សង្គមជាតិផងដែរ។



# ប.ស.ស ចុះអនុស្សារណៈជាមួយ ស.ស.យ.ក ដើម្បីពង្រឹងសុវត្ថិភាព ធ្វើដំណើររបស់បងប្អូនកម្មករនិយោជិត

**ភ្នំពេញ៖** បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) និងសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក) បានចុះអនុស្សារណៈយោគយល់គ្នា ក្នុងការលើកកម្ពស់សុវត្ថិភាពចរាចរណ៍ផ្លូវគោកក្នុងពេលធ្វើដំណើររបស់បងប្អូនកម្មករនិយោជិត កាលពីថ្ងៃចន្ទ ០១រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ដែលប្រារព្ធនៅសណ្ឋាគារភ្នំពេញ។




ពិធីនេះបានរៀបចំឡើង ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស និង **ឯកឧត្តម ហ៊ុន ម៉ានី** ប្រធានសហភាពសហ-ព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក) ព្រមទាំងមានការអញ្ជើញចូលរួមពីសមាជិក សមាជិកា ស្ថាប័នទាំងពីរ។




**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះ **ឯកឧត្តមប្រធាន ស.ស.យ.ក** និងបានជម្រាបជូនអំពីគោលបំណងនៃអនុ-ស្សារណៈនេះថា គឺមានគោលដៅដើម្បីបង្កើនកិច្ចសហប្រតិ-បត្តិការ ក្នុងការចូលរួមបណ្តុះបណ្តាល និងអនុវត្តផែនការ



សុវត្ថិភាពចរាចរណ៍ផ្លូវគោកសំដៅទប់ស្កាត់ និងកាត់បន្ថយចំនួនគ្រោះថ្នាក់ចរាចរណ៍របស់កម្មករនិយោជិតក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យនៅកម្រិតអប្បបរមា ព្រមទាំងប្ដេជ្ញារួមគ្នាអនុវត្តឱ្យទទួលបានជោគជ័យ។




**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានសម្ដែងនូវសេចក្ដីរីករាយ និងបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហការនេះ និងសង្ឃឹមជឿជាក់យ៉ាងមុតមាំថា ក្រោយពីចុះអនុស្សារណៈយោគយល់នេះរួចសមាជិក ប.ស.ស និងអ្នកបើកបររថយន្តដឹកកម្មករទទួលបានការអប់រំអំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក កាត់បន្ថយ និងទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍។




ប.ស.ស យកចិត្តទុកដាក់បំផុតចំពោះការងារចរាចរណ៍ដូចជា៖

- ចុះស្រង់ស្ថិតិអ្នកបើកបរយានយន្តដឹកកម្មករ ហើយបញ្ចូលជាសមាជិក ស.ស.យ.ក
- ចុះផ្សព្វផ្សាយអប់រំ ច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោកដល់កម្មករនិយោជិត អ្នកបើកបរយានយន្តដឹកកម្មករនៅតាមរោងចក្រ ប្រមូលផ្ដុំ និងនៅកន្លែងផ្សេងៗទៀត
- ចុះបណ្ដុះបណ្ដាលប្រឡងផ្ដល់បណ្ណបើកបរ និងឱ្យបណ្ណបើកបរស្របតាមប្រភេទយានយន្តដល់អ្នកបើកបរយានយន្តដឹកកម្មករ
- ចុះបណ្ដុះបណ្ដាលគ្រូបង្គោលផ្នែកសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដល់អ្នកបើកបរយានយន្តដឹកកម្មករ ប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋាន
- ចុះបណ្ដុះបណ្ដាលភ្នាក់ងារសង្គ្រោះបឋមដល់អ្នកបើកបរយានយន្តដឹកកម្មករ ប្រតិភូបុគ្គលិក សហជីពមូលដ្ឋាន និង គ្រូពេទ្យប្រចាំរោងចក្រ
- ចុះបំពាក់បដាពាក្យស្លោកនៅតាមរោងចក្រ
- ចុះសម្របសម្រួលពេលមានគ្រោះថ្នាក់ចរាចរណ៍



ជាមួយគ្នានេះដែរ **ឯកឧត្តមប្រធាន** បានឱ្យដឹងថា សហភាពសហព័ន្ធយុវជនកម្ពុជា បានបើកទំព័រថ្មីនៃភាពជោគជ័យមួយទៀតហើយនៃកិច្ចសហការនេះដើម្បីរួមចំណែកដល់ការបណ្ដុះបណ្ដាលអប់រំច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោកជូនដល់បងប្អូនកម្មករនិយោជិត និងអ្នកបើកបររថយន្តដឹកកម្មករឱ្យបានយល់ដឹងកាន់តែច្បាស់បន្ថែមទៀតពីសុវត្ថិភាពដឹកជញ្ជូនកម្មករនិយោជិត ត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តសុជីវធម៌ក្នុងការបើកបរ និងសកម្មភាពសំខាន់ៗចាំបាច់ផ្សេងទៀតតាមតម្រូវការជាក់ស្ដែង។




ជាកិច្ចបញ្ចប់ **ឯកឧត្តមប្រធាន** ក៏បានសម្ដែងនូវកិច្ចសហការយ៉ាងកក់ក្ដៅ និងការទទួលខុសត្រូវរបស់ស្ថាប័នទាំងពីរសម្រាប់កិច្ចសហការដ៏ល្អនេះ៕

# ពិធីប្រជុំបូកសរុបសមិទ្ធផល រយៈពេល ១០ឆ្នាំ និងទិសដៅការងារឆ្នាំ២០១៨ របស់បេឡាជាតិរបបសន្តិសុខសង្គម





**ភ្នំពេញ៖** នៅថ្ងៃអង្គារ ៥រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨ បានរៀបចំពិធីប្រជុំបូកសរុបសមិទ្ធផលរយៈពេល១០ឆ្នាំ (២០០៨-២០១៧) និងទិសដៅការងារឆ្នាំ២០១៨ របស់ខ្លួនក្រោមអធិបតីភាព **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម ដោយមានការចូលរួមពីបណ្តាក្រសួង ស្ថាប័ន អង្គភាព តំណាងឱ្យសមាគមនិយោជក អង្គការវិជ្ជាជីវៈ (សហជីព កម្មករនិយោជិត) មន្ទីរសុខាភិបាលរាជធានី/ខេត្ត មូលដ្ឋានសុខាភិបាលដែលជាដៃគូប្រមាណជាង ៤០០នាក់ ប្រព្រឹត្តទៅនៅសណ្ឋាគារភ្នំពេញ ។





**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** មានប្រសាសន៍ថាពិធីប្រជុំនេះត្រូវបានធ្វើឡើង ដើម្បីបង្ហាញអំពីសមិទ្ធផលការងារកន្លងទៅរយៈពេល១០ឆ្នាំ របស់ ប.ស.ស ដល់ក្រសួង ស្ថាប័ន អង្គភាព និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ដែលនឹងក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាពសម្រាប់វាស់វែងតាមដានវាយតម្លៃលើការអនុវត្តរបបសន្តិសុខសង្គម និងឈានដល់ការចូលរួមដោះស្រាយបញ្ហារួមគ្នាដែលនឹងកំណត់បានទិសដៅអនុវត្តការងារសម្រាប់ឆ្នាំ២០១៨ ឱ្យបានល្អប្រសើរបន្ថែមទៀតដូចខាងក្រោម៖



១. ផ្នែកបញ្ជិកា និងភាគទានទទួលបានការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានចំនួន ១០ ៨៤៩សហគ្រាស ស្មើនឹង ១ ៤៣៥ ៣១៦នាក់ ស្រីចំនួន ៨៦៨ ១៨៦នាក់ ទទួលបានភាគទានចំនួន ៤២៧ប៊ីលានរៀល។

បានផ្តល់តាវកាលិកជូនជនរងគ្រោះដោយហានិភ័យការងារសរុប ២០១ ៧៩៧(ដងនាក់) ចំណាយសរុបជាង ៧៦ប៊ីលានរៀល។

២. ផ្នែកថែទាំសុខភាព បានចុះកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញចំនួន ៣ ២៧១សហគ្រាស ស្មើនឹង ១ ១២១ ៤០៩នាក់ ស្រី ៨៤៨ ១២៦នាក់។ បានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលចំនួន ១ ២៩៥មូលដ្ឋាន រួមមានមន្ទីរពេទ្យថ្នាក់ជាតិចំនួន០៤ មន្ទីរពេទ្យបង្អែកចំនួន ១០៧ មណ្ឌលសុខភាពចំនួន ១ ១៦៩មូលដ្ឋាន មន្ទីរពេទ្យឯកជនចំនួន១៥មូលដ្ឋាន។ សមាជិកដែលបានទៅប្រើប្រាស់ចំនួន ៥៥៩ ៦៤៧ (ដងនាក់) ដែលដំណើរការនេះអាច វាយតម្លៃបានថាមានភាពរលូន និងប្រសិទ្ធភាពខ្ពស់។

៣. ផ្នែកប្រាក់សោធន នឹងដាក់ឱ្យដំណើរការនៅឆ្នាំ ២០១៩ ខាងមុខនេះ។

៤.ចំពោះការអនុវត្តរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ផ្នែកថែទាំសុខភាពត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៨ ផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៩។



៥. ការអនុវត្តផ្នែកថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន។ ក្នុងនោះបានចុះបញ្ជិកាសហគ្រាស និងកម្មករនិយោជិតក្រៅប្រព័ន្ធ (មូលនិធិសមធម៌) ចំនួន ២១ ៣៧៩សហគ្រាស មានកម្មករនិយោជិតជាសមាជិកចំនួន ១៨៤ ៤៣៦នាក់ ស្រី ២៧ ៦៦៥នាក់។ ការបើកផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូនទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ត្រូវដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៨។



**ទិសដៅការងារឆ្នាំ២០១៨៖**

១. ពង្រឹង និងពង្រីកការអនុវត្តផ្នែកហានិភ័យការងារបន្តពិនិត្យកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានា ស្របតាមទំហំការងារដែលកំពុងវិវឌ្ឍទៅមុខ សម្របសម្រួល ដោះស្រាយបញ្ហាប្រឈមដែលកើតមានឱ្យទាន់ពេលវេលា ពង្រឹងការអនុវត្តគោលនយោបាយវិស័យការងារ ដល់កន្លែងស្នាក់នៅដែលប្រមូលផ្តុំរបស់បងប្អូនកម្មករនិយោជិត ព្រមទាំងបន្តផ្សព្វផ្សាយគោលនយោបាយអនុវត្តន៍របបសន្តិសុខសង្គម អំពីសុវត្ថិភាពរបស់កម្មករនិយោជិត ទាំងនៅកន្លែងធ្វើការ និងពេលធ្វើដំណើរ។

២. ពង្រឹង និងពង្រីកការអនុវត្តផ្នែកថែទាំសុខភាព បន្តចុះកំណត់អត្តសញ្ញាណកម្មករជាថ្មីឱ្យអស់ក្នុងឆ្នាំនេះ បន្តចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលឱ្យកាន់តែទូលំទូលាយ សហការជាមួយមូលដ្ឋានសុខាភិបាល ដោះស្រាយរាល់បញ្ហាប្រឈមជាប្រចាំ ផ្សព្វផ្សាយគោលការណ៍អនុវត្តថ្មីៗ ឱ្យបានទូលំទូលាយ និងគ្រប់រូបភាព លើកកម្ពស់សេវាបង្ការសុខភាពដល់កម្មករចុះផ្សព្វផ្សាយអប់រំផ្ទាល់នៅនឹងកន្លែងការងារបង្កើនភ្នាក់ងារសម្របសម្រួល និងបរិក្ខារអេឡិចត្រូនិច តាមដៃគូមូលដ្ឋានសុខាភិបាលដែលមានកម្មករប្រើប្រាស់សេវាដ៏ច្រើន។

៣. ជម្រុញការរៀបចំ និងដាក់ឱ្យដំណើរការផ្នែកប្រាក់សោធនត្រូវរៀបចំដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៩។

៤. ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន៖

- ជម្រុញការចុះបញ្ជីមន្ត្រីសាធារណៈឱ្យអស់ក្នុងឆ្នាំនេះ
- ការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

៥. អនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិត ក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលដល់ស្ត្រីនៅពេលសម្រាលកូន៖

- និយោជក និងកម្មករនិយោជិត នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធត្រូវមកចុះបញ្ជិកាមកក្នុង ប.ស.ស ដើម្បីទទួលបានអត្ថប្រយោជន៍របបសន្តិសុខសង្គមនេះ
- សម្របសម្រួលផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមដល់ស្ត្រីសម្រាលកូនឱ្យបានឆាប់រហ័ស
- សម្របសម្រួលដោះស្រាយបញ្ហាប្រឈមជាប្រចាំភ្លាមៗជាមួយមូលដ្ឋានសុខាភិបាល តាមរយៈ កិច្ចប្រជុំនេះ។

បេឡាជាតិរបបសន្តិសុខសង្គម បានដោះស្រាយរួមគ្នានូវបញ្ហាប្រឈមនានា និងបានទទួលនូវព័ត៌មានសំខាន់ៗ ជាច្រើន ដែលជាធាតុចូលដ៏សំខាន់សម្រាប់កែលំអ ដើម្បីបន្តអភិវឌ្ឍ និងពង្រឹងប្រព័ន្ធគាំពារសង្គមឱ្យកាន់តែប្រសើរ និងមានប្រសិទ្ធភាពខ្ពស់ធានាបាននូវការផ្តល់សេវារដ្ឋបាលសាធារណៈនៃរបបសន្តិសុខសង្គម សម្រាប់កម្មករនិយោជិតបានកាន់តែប្រសើរមួយកម្រិតទៀត៕




ឯកឧត្តម អ៊ុក សមវិទ្យា នាយកប.ស.ស ឡើងថ្លែងសុន្ទរកថា អំពីទិសដៅការងារឆ្នាំ២០១៨ របស់បេឡាជាតិរបបសន្តិសុខសង្គម

# ប.ស.ស ផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល ជូនប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ នៅសាលាស្រុកស្វាយអន្ទរ





**ព្រៃវែង៖** នៅថ្ងៃអង្គារ ៣រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ត្រូវនឹងថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំពិធីប្រគល់បណ្ណមូលនិធិសមធម៌សុខាភិបាល ជូនក្រុមប្រឹក្សាឃុំ/សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិចំនួន ៤៦៧បណ្ណ នៅសាលាស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ក្រោមអធិបតីភាព **ឯកឧត្តម ប៉ែន នរៈវុធ** នាយករង ប.ស.ស និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ិត សមហិទ្ធា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក បេឡាជាតិរបបសន្តិសុខសង្គម និង **លោក ហេង ទ្រី** អភិបាលស្តីទីនៃគណៈអភិបាលស្រុកស្វាយអន្ទរ ។

ពិធីនេះត្រូវបានរៀបចំឡើង ក្រោយពីទទួលបានទិន្នន័យចុះបញ្ជិកាក្រុមប្រឹក្សាឃុំ/សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ កាលពីពេលថ្មីៗ កន្លងទៅនេះដោយមានការជម្រុញពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្នុងការយកចិត្តទុកដាក់លើបញ្ហាសុខភាព លោក លោកស្រី ជាថ្នាក់ដឹកនាំឃុំ/សង្កាត់ នៅទូទាំងប្រទេសប្រមាណជាង **៤៣ ០០០នាក់** ដើម្បីទទួល បានសេវាមូលនិធិសមធម៌សុខាភិបាល។

បន្ទាប់ពីទទួលបានបណ្ណមូលនិធិសមធម៌សុខាភិបាលនេះហើយ ក្រុមប្រឹក្សាឃុំ/សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ អាចទៅទទួលការពិនិត្យ និងព្យាបាលជំងឺនៅតាមមន្ទីរពេទ្យរដ្ឋទូទាំងប្រទេស ដោយឥតបង់ថ្លៃចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៨ នេះតទៅ៕



ឯកឧត្តម ប៉ែន នរៈវុធ ថតរូបអនុស្សាវរីយ៍ជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់ ប្រធានភូមិ អនុប្រធាភូមិ និងសមាជិកភូមិ នៅខេត្តព្រៃវែង

# កិច្ចប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម នៅខេត្តប៉ៃលិន



ឯកឧត្តម ម៉េង ហុង នាយករងប.ស.ស និងឯកឧត្តម ផាន់ ចាន់ធុល អភិបាលរងខេត្តប៉ៃលិន អញ្ជើញចូលរួមជាគណៈអធិបតី

**ប៉ៃលិន៖** បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃអង្គារ ១១កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ បានសហការជាមួយរដ្ឋបាលខេត្តប៉ៃលិន រៀបចំពិធីប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ដល់និយោជក ម្ចាស់សហគ្រាស និងគ្រឹះស្ថាន។



ឯកឧត្តម ផាន់ ចាន់ធុល អភិបាលរងខេត្តប៉ៃលិន

កិច្ចប្រជុំនេះដឹកនាំដោយ **ឯកឧត្តម ផាន់ ចាន់ធុល** អភិបាលរង ជាតំណាងឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន និង **ឯកឧត្តម ម៉េង ហុង** នាយករង ប.ស.ស និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ិត សំហេង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស ព្រមទាំងមានការអញ្ជើញចូលរួមពីមន្ទីរ អង្គភាព ចំណុះរដ្ឋបាលខេត្តប៉ៃលិន មន្ត្រី និងបុគ្គលិក សាខា ប.ស.ស ខេត្ត មូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀង និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថាន ឬតំណាង ជនរងគ្រោះដែលកំពុងទទួលបានតាវកាលិកបាត់បង់សមត្ថភាពអចិន្ត្រៃយ៍ និងឧត្តរជីវី (អ្នកនៅក្នុងបន្ទុក) សរុបប្រមាណជាង ១១៥នាក់ នៅសាលាខេត្តប៉ៃលិន។


សកម្មភាពអ្នកចូលរួមប្រជុំផ្សព្វផ្សាយរបស់ ប.ស.ស

កម្មវិធីនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីវឌ្ឍនភាព ប.ស.ស ក៏ដូចជាបញ្ហាប្រឈម ដំណោះស្រាយ និងទិសដៅអនុវត្តបន្តរបស់ ប.ស.ស ជាពិសេសអត្ថប្រយោជន៍ដែលទទួលបានពី ប.ស.ស។



ឯកឧត្តម ម៉េង ហុង ឡើងមានមតិក្នុងកិច្ចប្រជុំ

**ឯកឧត្តមនាយករង** បានលើកឡើងពីប្រវត្តិ ប.ស.ស និងច្បាប់របបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយណាស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលបង្កើតឡើងដោយព្រះរាជក្រមលេខៈ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២។ ប.ស.ស ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧។ **ឯកឧត្តម** បានបន្តទៀតថា បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាលមានបេសកកម្មបម្រើសេវាផ្នែកសាធារណៈជាលក្ខណៈសង្គម ដែលមាន០៣ ផ្នែករួមមានផ្នែកទី១ ហានិភ័យការងារ ផ្នែកទី២ថែទាំសុខភាព និងផ្នែកទី៣ ប្រាក់សោធន។ ផ្នែកហានិភ័យ ការងារត្រូវបានអនុវត្តតាំងពីឆ្នាំ២០០៨រហូតមកដល់បច្ចុប្បន្ន។

បេឡាជាតិរបបសន្តិសុខសង្គមបានចុះបញ្ជិកា សហគ្រាស គ្រឹះស្ថានចំនួន ១១ ៥១៤សហគ្រាស និងកម្មករនិយោជិតចំនួន ១ ៤៤៨ ៦០៥នាក់ ក្នុងនោះគ្រោះថ្នាក់ការងារទូទាំងប្រទេស ចំនួន ១៩០ ៦៧០នាក់ បានចំណាយថវិកាក្នុងការផ្តល់តាវកាលិកប្រមាណជាង ៧៨ប៊ីលានរៀល និងចំណាយលើវិភាជន៍បូជាសពដល់ជនរងគ្រោះចំនួន ៩១៤នាក់ សរុបជា


សកម្មភាពអ្នកចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយ

ប្រមាណចំនួន ៣ប៊ីលានរៀល។ ចំណែកឯ ផ្នែកថែទាំសុខភាព បានចាប់ផ្តើមអនុវត្តន៍ចាប់តាំងពីខែឧសភា ឆ្នាំ២០១៦ និង បានមកចុះបញ្ជិកាចំនួន ៥ ៦៧០សហគ្រាស ដែលមានកម្មករនិយោជិតសរុបចំនួន ១ ៣១៨ ៤១៨នាក់ ស្រី ៩៦៨ ៧៨១ នាក់ គិតត្រឹមខែមីនា ឆ្នាំ២០១៨នេះ។

ជាមួយគ្នានេះដែរ ដើម្បីបង្កលក្ខណៈងាយស្រួល និង បង្កើនការផ្តល់សេវាឱ្យបានទាន់ពេលវេលា ប.ស.ស បានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលសាធារណៈមានចំនួន ១ ៣០០មូលដ្ឋានទូទាំងប្រទេស៕


សកម្មភាពអ្នកចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយ

# បេឡាជាតិរបបសន្តិសុខសង្គម ផ្តល់បណ្ណសមាជិក ដល់បុគ្គលិកប៊ែលធី ចំនួន ៥១៨នាក់

**ភ្នំពេញ៖** នៅថ្ងៃពុធ ៤កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៨ បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំពិធីប្រគល់បណ្ណសមាជិក ប.ស.ស ដល់បុគ្គលិកប៊ែលធី និងធ្វើបទបង្ហាញស្តីពីការផ្តល់តាវកាលិកថែទាំសុខភាពស្ថិតនៅសាកលវិទ្យាល័យប៊ែលធីអន្តរជាតិ។

ពិធីនេះរៀបចំឡើងក្រោមអធិបតីភាព **ឯកឧត្តម ម៉េង ហុង** នាយករង ប.ស.ស និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស និង **ឯកឧត្តម លី ឆេង** ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ជាអគ្គនាយកប៊ែលធីគ្រុប និងជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យប៊ែលធី ព្រមទាំងមានការអញ្ជើញចូលរួមពីមន្ត្រី និងបុគ្គលិកចំនួន ៥១៨នាក់។


ឯកឧត្តម ម៉េង ហុង ឯកឧត្តម លី ឆេង


ការចូលរួមរបស់មន្ត្រី និងបុគ្គលិក របស់ប៊ែលធីគ្រុប


លោក ខាត់ សឿន ប្រធានការិយាល័យរដ្ឋបាល ប៊ែលធីគ្រុប

**លោក ខាត់ សឿន** ប្រធានការិយាល័យរដ្ឋបាលប៊ែលធីគ្រុប មានប្រសាសន៍ថា ដោយមានការយកចិត្តទុកដាក់បន្ថែមពីសំណាក់ ឯកឧត្តមអគ្គនាយកប៊ែលធីគ្រុប និងលោកលោកស្រី គណៈគ្រប់គ្រង និងបុគ្គលិកប៊ែលធីគ្រុប បានចុះបញ្ជិកា សហគ្រាស គ្រឹះស្ថានមកក្នុង ប.ស.ស ចាប់ពីឆ្នាំ ២០០៩ មក និងបានបង់ភាគទានមក ប.ស.ស ជារៀងរាល់ខែ ដើម្បីទទួលបានសេវារ៉ាប់រងលើផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពពី ប.ស.ស ។

**លោក សុក បូរ៉ា** ប្រធានការិយាល័យតាវកាលិក នៃបេឡាជាតិរបបសន្តិសុខសង្គម បានធ្វើបទបង្ហាញអំពីនីតិ-វិធីនៃការប្រើប្រាស់បណ្ណសមាជិក ប.ស.ស និងការផ្តល់កញ្ចប់តាវកាលិក ថែទាំសុខភាព សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ សេវាសង្គ្រោះបន្ទាន់ សេវាបង្ការសុខភាព សេវាសម្រាលកូន និងប្រាក់បំណាច់ប្រចាំថ្ងៃ។


លោក សុក បូរ៉ា ប្រធានការិយាល័យតាវកាលិក នៃ ប.ស.ស



ឯកឧត្តម លី ឆេង ឡើងថ្លែងមតិស្វាគមន៍ក្នុងពិធីប្រជុំ



ឯកឧត្តម ម៉េង ហុង មានប្រសាសន៍ក្នុងកិច្ចប្រជុំ

**ឯកឧត្តម លី ឆេង** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យប៊ែលធី មានប្រសាសន៍ថា ថ្ងៃនេះបេឡាជាតិរបបសន្តិសុខសង្គម បានផ្តល់បណ្ណសមាជិក ផ្នែកថែទាំសុខភាពដល់លោកគ្រូ អ្នកគ្រូ និងបុគ្គលិក ដើម្បីជាការលើកទឹកចិត្តក្នុងការខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួន ដោយមិនព្រួយបារម្ភពីការចំណាយលើថ្លៃព្យាបាល ក្នុងករណីមានគ្រោះថ្នាក់ជាយថាហេតុណាមួយ។



ឯកឧត្តម ម៉េង ហុង ប្រគល់បណ្ណសមាជិក ប.ស.ស

ថ្លែងទៅកាន់អង្គពិធី **ឯកឧត្តម ម៉េង ហុង** មានប្រសាសន៍ថា យោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានជម្រុញឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមាន ប.ស.ស ជាសេនាធិការត្រូវយកចិត្តទុកដាក់លើការបើកផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជ-រដ្ឋាភិបាលដល់កម្មការិនី ទាំងក្នុង និងក្រៅប្រព័ន្ធ ដែលសម្រាលកូនឱ្យទាន់ពេលវេលា។

**ឯកឧត្តម** បន្តទៀតថា **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសដាក់ចេញ គោលនយោបាយថ្មីរបស់រាជរដ្ឋាភិបាលនូវថវិកាឧបត្ថម្ភបន្ថែមដល់កម្មការិនីដែលសម្រាលកូន ក្នុងនោះចំពោះកម្មការិនីសម្រាលបាន កូនម្នាក់ទទួលបានថវិកា ៤០០ ០០០រៀល សម្រាលបាន កូនភ្លោះពីរទទួលបានថវិកា ៨០០ ០០០រៀល និងសម្រាលបាន កូនភ្លោះបីទទួលបានថវិកា ១ ២០០ ០០០ រៀល រួមទាំងថវិកា ៥លានរៀល បន្ថែមទៀតពី **សម្តេច តេជោ** ទោះបីសម្រាលមកស្លាប់ក៏ដោយក៏ទទួលបានដូចគ្នា៕







# កិច្ចប្រជុំផ្សព្វផ្សាយ
## អំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គមនៅខេត្តកំពង់ធំ

**កំពង់ធំ៖** ថ្ងៃសុក្រ ១៣កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៨ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយរដ្ឋបាលខេត្តកំពង់ធំ រៀបចំពិធីប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គមដល់តំណាង ម្ចាស់សហគ្រាស គ្រឹះស្ថាន។

កិច្ចប្រជុំផ្សព្វផ្សាយ នេះ ប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម សុខ ហៃ** អភិបាលរង និងជាតំណាងឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ និង **ឯកឧត្តម ម៉េង ហុង** នាយករង ប.ស.ស តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស ព្រមទាំងមានការអញ្ជើញចូលរួមពីលោក លោកស្រី ប្រធានមន្ទីរ អង្គភាពចំណុះរដ្ឋបាលខេត្តកំពង់ធំ មន្ត្រី និងបុគ្គលិក សាខា ប.ស.ស ខេត្ត មូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀង តំណាងនិយោជក ម្ចាស់សហគ្រាស គ្រឹះស្ថាន និងតំណាងជនរងគ្រោះដែលកំពុងទទួលបានតាវកាលិកបាត់បង់សមត្ថភាពអចិន្ត្រៃយ៍ និងឧត្តរជីវី (អ្នកនៅក្នុងបន្ទុក) សរុបប្រមាណជាង ២០០នាក់ នៅសាលាខេត្តកំពង់ធំ។





សកម្មភាពអ្នកចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយ

ផ្តើមចេញពីនេះ **ឯកឧត្តម សុខ ហៃ** អភិបាលរងខេត្ត បានថ្លែងអំណរគុណដល់បេឡាជាតិរបបសន្តិសុខសង្គមដែលបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយនេះឡើង ពិសេសទាក់ទងទៅនិងការធានារ៉ាប់រងលើរបបសន្តិសុខសង្គម សម្រាប់កម្មករ



និយោជិតទាំងក្នុង និងក្រៅប្រព័ន្ធ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងគោលនយោបាយ កាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលតាមរយៈការបន្ថយនូវគម្លាតប្រាក់ចំណូលរវាងអ្នកមាន និងអ្នកក្រ ដើម្បីធានាស្ថិរភាព និងភាពសុខដុមរមនានៅក្នុងសង្គម។

ជាមួយគ្នានេះ **ឯកឧត្តម ម៉េង ហុង** បានថ្លែងបញ្ជាក់ថា ៖ បេឡាជាតិរបបសន្តិសុខសង្គម មានសាខាទាំង ២៥ ខេត្ត /ក្រុង នៅទូទាំងប្រទេស បច្ចុប្បន្នផ្នែកហានិភ័យការងារ មានសហគ្រាស សរុបចំនួន ១១ ៦៩៦សហគ្រាស បានចុះបញ្ជិកា ដែលមានសមាជិកសរុប ១ ៤៥២ ៣៤១នាក់ និងបានចុះកិច្ចព្រមព្រៀងជាមួយមន្ទីរពេទ្យ មណ្ឌលសុខភាព ក្នុងការផ្តល់សេវាជូនសមាជិក ប.ស.ស ចំនួន ១ ៣១៧មូលដ្ឋានសុខាភិបាលផងដែរ។ ទន្ទឹមគ្នានេះតាវកាលិកដែលសមាជិក ប.ស.ស អាចទទួលបានរួមមាន៖ សេវាសង្គ្រោះបន្ទាន់ សេវាថែទាំ និងព្យាបាល ទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ ទទួលបានប្រាក់ធនលាភ និងប្រាក់វិភាជន៍សោហ៊ុយបូជាសព តាវកាលិកឧត្តរជីវី សេវាបុននីតិសម្បទា និងការសម្របសម្រួលវិជ្ជាជីវៈឡើងវិញ។



ដោយឡែកផ្នែកថែទាំសុខភាព គឺដល់ការធានារ៉ាប់រងសុខភាពសង្គមដូចជា៖ សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ សេវាបង្ការសុខភាព ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការអាក់ខានការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។

បើគិតរហូតមកដល់ពេលបច្ចុប្បន្ននេះ មានសហគ្រាសចុះបញ្ជិកាចំនួន ៦ ១៦៣សហគ្រាស ដែលមានសមាជិកចំនួន១ ៣៤៨ ៨១៨នាក់ស្រី ៩៨៣ ២១៧នាក់។

បន្ថែមពីនេះទៀត **ឯកឧត្តម** បានលើកឡើងផងដែរ ស្តីពីអនុក្រឹតលេខ១៤០ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៧ នៃអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ ពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញាត្តិនៃច្បាប់ស្តីពីការងារ។



ដូច្នេះសម្រាប់និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថានគប្បីមានការ យល់ដឹងកាន់តែច្បាស់ ពីការបង្ការគ្រោះថ្នាក់ការងារ ការយកចិត្តទុកដាក់ពីសុខភាព សុវត្ថិភាពអនាម័យ និងសុវត្ថិភាពក្នុងពេលធ្វើដំណើរទៅនិងមកពីបំពេញភារកិច្ចរបស់បុគ្គលិក កម្មករនិយោជិត នៅតាមសហគ្រាស គ្រឹះស្ថានដែលពាក់ព័ន្ធនឹងការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ ការផ្តល់សេវារបស់មន្ត្រី ប.ស.ស សាខាខេត្ត សេវាសុខាភិបាលរបស់មន្ទីរពេទ្យដែលចុះកិច្ចព្រមព្រៀង ព្រមទាំងការផ្តល់សេវាពាក់ពន្ធ័ និងធនាគារអេស៊ីលីដាភីអិលស៊ី ធនាគារកាណាឌីយ៉ា ធនាគារឯកទេសវីង ដែលជាដៃគូក្នុងការផ្តល់សេវាទាំងនេះផងដែរ៕

# ពិធីប្រគល់បណ្ណមូលនិធិសមធម៌សុខាភិបាល និងបណ្ណចេញចូលបរិវេណតំបន់សេដ្ឋកិច្ចពិសេស នៅខេត្តព្រះសីហនុ

ព្រះសីហនុ៖ នៅថ្ងៃព្រហស្បតិ៍ ០៦កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **ឯកឧត្តម ជាវ ប៊ុនរិទ្ធ** អ្នកនាំពាក្យ ប.ស.ស និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស បានអញ្ជើញជាអធិបតីភាពក្នុងពិធីប្រគល់បណ្ណមូលនិធិសមធម៌សុខាភិបាល និងបណ្ណចេញចូលបរិវេណតំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ ដោយមានការអញ្ជើញចូលរួមពីប្រធានមន្ទីរការងារបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ត្រី បុគ្គលិករបស់ ប.ស.ស តំណាងរោងចក្រ ប្រធានសមាគមអ្នកបើកឡានដឹកកម្មករ និងបងប្អូនអ្នកបើកឡានដឹកកម្មករ ប្រមាណជាង២០០នាក់។



ឯកឧត្តម ជាវ ប៊ុនរិទ្ធ អញ្ជើញជាអធិបតីក្នុងពិធីចែកបណ្ណ



ឯកឧត្តម ជាវ ប៊ុនរិទ្ធ មានប្រសាសន៍ក្នុងអង្គពិធី

**ឯកឧត្តម ជាវ ប៊ុនរិទ្ធ** បានមានប្រសាសន៍ថា ពិធីនេះត្រូវបានធ្វើឡើង ក្នុងគោលបំណងផ្តល់បណ្ណចេញ-ចូលបរិវេណតំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ ក្នុងការដឹកជញ្ជូនកម្មករនិយោជិតឱ្យមានសុវត្ថិភាពខ្ពស់ ដោយ ប.ស.ស បានសហការជាមួយម្ចាស់តំបន់។

ពិសេសជាងនេះទៀត ប.ស.ស បានផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាលចំនួន ១៩៦បណ្ណ ដល់សមាជិកសមាគមអ្នកបើកបរឡានដឹកកម្មករ។ ចំពោះការផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាលនេះធ្វើឡើងក្រោយពីទទួលបានទិន្នន័យរបស់អ្នកបើកឡានដឹកកម្មករ នៅក្រោមកិច្ចសហការពីម្ចាស់តំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ និងសមាគមអ្នកបើកឡានដឹកកម្មករ។

បើយោងតាមរបាយការណ៍ប្រជុំបូកសរុបសមិទ្ធផលការងារសម្រេចបានឆ្នាំ២០១៧ របស់ក្រុមការងារ ស.ផ.ក បានបង្ហាញថា គ្រោះថ្នាក់ចរាចរណ៍ធ្លាក់លើកម្មករនិយោជិតមានចំនួន **១ ៧៧១ករណី** បណ្តាលឱ្យស្ត្រីរងរបួសសរុបចំនួន **២ ៣២៦នាក់** ក្នុងនោះរបួសធ្ងន់ចំនួន **៣២០នាក់** និងរបួសស្រាលចំនួន **១ ៩៧០នាក់** ព្រមទាំងស្លាប់ចំនួន **៣៦នាក់**។ ករណីគ្រោះថ្នាក់ចរាចរណ៍នេះ បង្កឡើងដោយកត្តាម៉ូតូមានចំនួន **៨៧.៦២**% កត្តារថយន្ត ចំនួន **៣.៩៦**% និងកត្តាផ្សេងៗចំនួន **៨.៤២**%។



សកម្មភាពអ្នកចូលរួមក្នុងកិច្ចប្រជុំ

**ឯកឧត្តម** បានបន្តថា ដោយមានកិច្ចសហការពីម្ចាស់តំបន់សេដ្ឋកិច្ចពិសេស ខេត្តព្រះសីហនុ ប.ស.ស បានរៀបចំពិធីផ្តល់បណ្ណចេញចូលបរិវេណក្រុមហ៊ុន និងផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាលដល់បងប្អូនអ្នកបើកឡានដឹកកម្មករ ដែលអាចទៅទទួលសេវាពិនិត្យ និងព្យាបាលជំងឺ ដោយឥតគិតថ្លៃ នៅមូលដ្ឋានសុខភាពភិបាលសាធារណៈ(មន្ទីរពេទ្យរដ្ឋ)

នៅទូទាំងប្រទេស។ ទាំងនេះ ដោយមានការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានបេឡាជាតិរបបសន្តិសុខសង្គម ជាសេនាធិការអនុវត្តលើប្រព័ន្ធគាំពារសង្គមប្រកបដោយប្រសិទ្ធភាពខ្ពស់។







**ឯកឧត្តម** បានបន្ថែមទៀតថា ដោយបានទទួលគោលការណ៍ពី **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា **ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨** ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ និងក្រុមប្រឹក្សាឃុំ/សង្កាត់ អាចទៅទទួលការពិនិត្យ និងព្យាបាលជំងឺនៅតាមមន្ទីរពេទ្យរដ្ឋទូទាំងប្រទេសដោយឥតបង់ថ្លៃ។

ជាពិសេសជាងនេះទៅទៀត **សម្តេចតេជោ** បានឧបត្ថម្ភគោលរបបជាសាច់ប្រាក់សុទ្ធដល់កម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធ ដែលបានចុះបញ្ជីជាមួយ ប.ស.ស។ សម្រាប់ស្ត្រីពេលសម្រាលបានកូន **១នាក់ នឹងទទួលបានថវិកាឧបត្ថម្ភ ចំនួន ៤០ម៉ឺនរៀល** សម្រាលបានកូនភ្លោះ**២នាក់ ទទួលបានថវិកាឧបត្ថម្ភ ចំនួន ៨០ម៉ឺនរៀល** សម្រាលបានកូនភ្លោះ**៣នាក់ ទទួលបានថវិកាឧបត្ថម្ភចំនួន ១លាន ២០ម៉ឺនរៀល** ជាងនេះទៅទៀត អ្វីដែលត្រេកអរបំផុតនោះគឺ កូនភ្លោះ៣នាក់ ជាកូនរបស់ **សម្តេចតេជោ** នឹងទទួលបានប្រាក់ឧបត្ថម្ភបន្ថែមចំនួន **៥លានរៀល**៕



# ពិធីប្រគល់បណ្ណមូលនិធិសមធម៌សុខាភិបាល និងបណ្ណសម្គាល់យានយន្តដល់អ្នកបើកបរដឹកកម្មករ ក្នុងតំបន់សេដ្ឋកិច្ចពិសេស តាយ សេង




**ស្វាយរៀង៖** នៅថ្ងៃសៅរ៍ ១៤កើត ខែពិសាខ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៨ **ឯកឧត្តម ជាវ ប៊ុនរិទ្ធ** ប្រធានការិយាល័យគោលនយោបាយ និងជាសមាជិកក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត បានអញ្ជើញជាអធិបតីភាពក្នុងពិធី ប្រគល់បណ្ណមូលនិធិសមធម៌សុខាភិបាល និងផ្តល់បណ្ណសម្គាល់យានយន្តសម្រាប់ចេញ-ចូលតំបន់ជូនដល់អ្នកបើកបររថយន្តដឹកកម្មករចំនួនជាង ៣៤០នាក់។


ឯកឧត្តម ជាវ ប៊ុនរិទ្ធ ជាតំណាងក្នុងការប្រគល់បណ្ណ


សកម្មភាពអ្នកចូលរួមក្នុងកិច្ចប្រជុំ

ពិធីនេះត្រូវបានរៀបចំឡើង ក្នុងគោលបំណងផ្តល់បណ្ណសម្គាល់យានយន្តសម្រាប់ចេញ-ចូលបរិវេណតំបន់សេដ្ឋកិច្ចពិសេសដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការចេញចូលរថយន្តដឹកកម្មករ និងបានផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាលដល់អ្នកបើកបររថយន្តដឹកកម្មករឱ្យគាត់មានសិទ្ធិទៅ ប្រើសេវាពិនិត្យ និងព្យាបាលជំងឺនៅតាមមន្ទីរពេទ្យរដ្ឋ នៅទូទាំងប្រទេសដោយឥតគិតថ្លៃ។

**ឯកឧត្តម** បានបញ្ជាក់បន្ថែមថា ដើម្បីរួមចំណែកជួយសម្រាលបន្ទុកនេះ ប.ស.ស បានរៀបចំបណ្តុះបណ្តាល និងផ្សព្វផ្សាយអប់រំច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដល់កម្មករនិយោជិត និងអ្នកបើកបររួមមាន៖

- បណ្តុះបណ្តាលគ្រូបង្គោល **១០លើក** ស្មើនឹង **៧៣១នាក់**
- បណ្តុះបណ្តាលភ្នាក់ងារសង្គ្រោះបឋម **០៣លើក** ស្មើនឹង **១៣២នាក់**
- ប្រជុំផ្សព្វផ្សាយអប់រំ **១ ០៩០លើក** ស្មើនឹង **១៨៣ ៦៩១នាក់**
- បណ្តុះបណ្តាល និងបំប៉នលើសមត្ថភាពសម្រាប់ត្រៀមប្រឡងយកបណ្ណបើកបរ **១៥០លើក** ស្មើនឹង **៩ ១៨៤នាក់**
- ការប្រឡងយកបណ្ណបើកបរ **៤០លើក** ស្មើនឹង **៣ ១២៣នាក់** ជាប់ជាស្ថាពរចំនួន **២ ០៦០នាក់**
- ចែកបណ្ណបើកបរ ដល់អ្នកបើកបររថយន្តដឹកកម្មករ **២៣លើក** ស្មើនឹង **២ ០៦០នាក់**
- បំពាក់បដាពាក្យស្លោកនៅតាមរោងចក្រ ១៤០ រោងចក្រ ស្មើនឹង ១៤៦បដា
- ចែកបណ្ណមូលនិធិសមធម៌សុខាភិបាល ២ ៥៤៧ បណ្ណ និងបណ្ណសម្គាល់យានយន្តសម្រាប់ចេញ-ចូល ១ ៨៩៥បណ្ណ។


ឯកឧត្តម ជាវ ប៊ុនរិទ្ធ មានប្រសាសន៍ក្នុងពិធី

**ឯកឧត្តម ជាវ ប៊ុនរិទ្ធ** បានសម្តែងសេចក្តីសោមនស្សរីករាយបំផុតដល់ម្ចាស់តំបន់សេដ្ឋកិច្ចពិសេស តាយ សេង និងថៅកែរោងចក្រ A and J (Cambodia) Co., Ltd ដែលបានចូលរួមសហការជាមួយ ប.ស.ស ក្នុងការផ្តល់ទីតាំងប្រារព្ធពិធីសម្រាប់អ្នកបើកបររថយន្តដឹកកម្មករនិយោជិត។

ជាចុងក្រោយ **ឯកឧត្តម** ក៏បានសំណូមពរដល់បងប្អូនជាអ្នកបើកបររថយន្តដឹកកម្មករនិយោជិតឱ្យចូលរួមគោរពច្បាប់ចរាចរណ៍ និងអនុវត្តនូវក្រមសីលធម៌ទាំង ១០ចំណុច របស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកឱ្យបានបានខ្ជាប់ខ្ជួនដើម្បីរក្សាសុវត្ថិភាពផ្ទាល់ខ្លួន និងសុវត្ថិភាពបងប្អូនដែលជាកម្មករ កម្មការិនី នៅពេលធ្វើដំណើរពីផ្ទះទៅកន្លែងធ្វើការ និងពីកន្លែងធ្វើការត្រលប់ទៅផ្ទះវិញ ៕



ឯកឧត្តម ជាវ ប៊ុនរិទ្ធ ផ្តល់បណ្ណចេញ-ចូល និងបណ្ណមូលនិធិសមធម៌សុខាភិបាល ជូនបងប្អូនអ្នកបើកបររថយន្តដឹកកម្មករ




# ពិធីផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាលជូនប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ នៅសាលាស្រុកក្រូចឆ្មារ

**ត្បូងឃ្មុំ៖** នៅថ្ងៃសៅរ៍ ៩រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធីបតីភាព **លោក ហែម សុគន្ធារិន** អនុប្រធានការិយាល័យគោលនយោបាយ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម និងលោក **ស្រេង លី** អភិបាល នៃគណៈអភិបាលស្រុកក្រូចឆ្មារ បានអញ្ជើញជាអធិបតីភាពក្នុងពិធីផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាលជូនដល់ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ និងក្រុមប្រឹក្សាឃុំ/សង្កាត់ចំនួន ២៤៩បណ្ណ ប្រារព្ធធ្វើនៅសាលាស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។

**លោក ហែម សុគន្ធារិន** បានមានប្រសាសន៍ថា កម្មវិធីនេះត្រូវបានរៀបចំឡើង ក្រោយពីទទួលបានទិន្នន័យចុះបញ្ជិកា ក្រុមប្រឹក្សាឃុំ/សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ កាលពីពេលថ្មីៗកន្លងទៅនេះដោយមានការជម្រុញពីប្រមុខរាជរដ្ឋាភិបាលកម្ពុជាក្នុងការយកចិត្តទុកដាក់លើបញ្ហាសុខភាពថ្នាក់ដឹកនាំ ឃុំ/សង្កាត់ នៅទូទាំងប្រទេសប្រមាណជាង ៤៣ ០០០នាក់ ដើម្បីទទួលបានសេវាមូលនិធិសមធម៌សុខាភិបាល។

បន្ទាប់ពីទទួលបានបណ្ណមូលនិធិសមធម៌សុខាភិបាលនេះហើយ ក្រុមប្រឹក្សាឃុំ/សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ អាចទៅទទួលការពិនិត្យ និងព្យាលបាលជំងឺនៅតាមមន្ទីរពេទ្យរដ្ឋទូទាំងប្រទេសដោយឥតបង់ថ្លៃ ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៨ នេះតទៅ៕


លោក ហែម សុគន្ធារិន ឡើងមានប្រសាសន៍ក្នុងពិធីប្រគល់បណ្ណ

# សកម្មភាពក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកចុះផ្សព្វផ្សាយពីច្បាប់ចរាចរណ៍ និងផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល

## សកម្មភាពក្រុមការងារ ប.ស.ស ផ្តល់បណ្ណមូលនិធិសមធម៌ដល់អ្នកបើកបរ នៅខេត្តកណ្តាល

**កណ្ដាល៖** នៅថ្ងៃចន្ទ ៣កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) នៃបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល និងបណ្ណសម្គាល់យានយន្ត ចេញ-ចូលដល់អ្នកបើកបរឡានដឹកកម្មករនិយោជិតនៅតំបន់សួនឧស្សាហកម្ម សំរោងធំ ដោយមានអ្នកចូលរួមជាង ៦០នាក់ ស្ថិតនៅ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល។

គោលបំណងនៃការផ្តល់បណ្ណនេះ ដើម្បីឱ្យអ្នកបើកបរយានយន្តដឹកកម្មករនិយោជិតទទួលបានសេវាពិនិត្យ និងព្យា-បាលជំងឺនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈដោយឥតគិតថ្លៃ៕





ក្រុមការងារ ស.ផ.ក ពន្យល់ច្បាប់ចរាចរណ៍ នៅខេត្តកណ្ដាល

## សកម្មភាពក្រុមការងារ ប.ស.ស ផ្តល់បណ្ណមូលនិធិសមធម៌ដល់អ្នកបើកបរ នៅកំពង់ឆ្នាំង

**កំពង់ឆ្នាំង៖** នៅថ្ងៃសុក្រ ៦រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) នៃបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះប្រជុំផ្សព្វ-ផ្សាយស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងគោលនយោបាយបេឡាជាតិរបបសន្តិសុខសង្គមព្រមទាំងផ្តល់បណ្ណមូលនិធិសម-ធម៌សុខាភិបាលជូនអ្នកបើកបរយានយន្តនៅរោងចក្រ អ៊ិម វេ អ៊ិនធឺណេត ស៊ិនណាល ម៉េនញ៉ូហ្វេកធឺរីង (M&V INTERNA-TIONAL MANUFACTURING CO., LTD) ស្ថិតនៅភូមិត្រពាំងចឹកសា សង្កាត់កំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។

គោលបំណងនៃការផ្តល់បណ្ណ ដើម្បីឱ្យអ្នកបើកបរយានយន្តដឹកកម្មករនិយោជិតទទួលបានសេវាពិនិត្យ និងព្យាបាលជំងឺ នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈដោយឥតគិតថ្លៃ៕



ក្រុមការងារផ្ដល់បណ្ណមូលនិធិសមធម៌សុខាភិបាល នៅខេត្តកំពង់ឆ្នាំង



អ្នកបើកបររថយន្តដឹកកម្មករ ចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយ នៅខេត្តកំពង់ឆ្នាំង

## សកម្មភាពក្រុមការងារចុះផ្សព្វផ្សាយ នៅរាជធានីភ្នំពេញ

**ភ្នំពេញ៖** ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) នៃបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃសុក្រ ០៦រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ នេះ បានចុះបណ្តុះបណ្តាលច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរឡានដឹកកម្មករនិយោជិត នៅរោងចក្រ **វីនណាស់ ហ្គាមិន ខូ អិលធីឌី** (WINAS GRAMENT CO., LTD) ស្ថិតនៅខណ្ឌសែនសុខ រាជធានីភ្នំពេញ។

គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ ដើម្បីបញ្ជ្រាបចំណេះដឹងអំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់អ្នកបើកបរជម្រុញឱ្យមានការ គោរពច្បាប់ឱ្យបានត្រឹមត្រូវ និងចូលរួមកាត់បន្ថយ គ្រោះថ្នាក់ចរាចរណ៍ទូទាំងប្រទេស ។


ក្រុមការងារ ប.ស.ស ប្រជុំផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍


ក្រុមការងារ ប.ស.ស ប្រជុំផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍

## សកម្មភាពក្រុមការងារចុះផ្សព្វផ្សាយ នៅខេត្តតាកែវ

**តាកែវ៖** នៅថ្ងៃសុក្រ ៦រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោ-ជិត (ស.ផ.ក) នៃបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល ជូនអ្នកបើកបរយានយន្តដឹកកម្មករចំនួន **៦៣បណ្ណ** នៅរោងចក្រ អាយ ឆេង ខេមបូឌា ខបភឺរេតស៊ិន I-CHENG (CAMBODIA) CORPORATION CO.,LTD និងរោងចក្រ គួនតិច (ខេមបូឌា) ខូបភឺរេតសិន លីមីតធីត ខូ អិលធីឌី KUANTECH (CAMBODIA) CORPORATION CO.,LIMITED ស្ថិតនៅស្រុកបាទី និងស្រុកត្រាំកក់ ខេត្តតាកែវ។

គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ ដើម្បីបញ្ជ្រាបចំណេះដឹងអំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់អ្នកបើកបរជម្រុញឱ្យមានការគោរពច្បាប់ឱ្យបានត្រឹមត្រូវ និងចូលរួមកាត់បន្ថយ គ្រោះថ្នាក់ចរាចរណ៍ទូទាំងប្រទេស និងដើម្បីផ្តល់បណ្ណឱ្យអ្នកបើកបរយានយន្តដឹកកម្មករនិយោជិត ទទួលបានសេវាពិនិត្យ និងព្យាបាល ជំងឺនៅតាមមន្ទីររដ្ឋដោយឥតគិតថ្លៃ៕



ក្រុមការងារ ស.ផ.ក ផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល នៅខេត្តតាកែវ


អ្នកចូលរួមក្នុងកម្មវិធីប្រជុំផ្សព្វផ្សាយសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅខេត្តតាកែវ

# សកម្មភាពក្រុមការងារ បេឡាជាតិរបបសន្តិសុខសង្គម សាខាខេត្ត ចុះកំណត់អត្តសញ្ញាណកម្មករនិយោជិត

## សកម្មភាពក្រុមការងារចុះកំណត់អត្តសញ្ញាណ នៅខេត្តរតនគិរី

**រតនគិរី៖** នៅថ្ងៃចន្ទ ៣កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សាខាខេត្តរតនគិរី បានចុះកំណត់អត្តសញ្ញាណកម្មករនិយោជិតនៅ ក្រុមហ៊ុនម៉េស្គូហ្គោ ដែលមានកម្មករនិយោជិតទើបចូលធ្វើការថ្មីចំនួន **៧៥នាក់** ស្ត្រី **០៣នាក់** ៕


ក្រុមការងារកំណត់អត្តសញ្ញាណកម្មករនិយោជិតនៅខេត្តរតនគិរី

## សកម្មភាពក្រុមការងារចុះកំណត់អត្តសញ្ញាណ នៅខេត្តស្វាយរៀង

**ស្វាយរៀង៖** នៅថ្ងៃព្រហស្បតិ៍ ០៦កើត ខែចេត្រ ឆ្នាំ រកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ សាខាខេត្តស្វាយរៀង បានចុះកំណត់អត្ត-សញ្ញាណកម្មករនិយោជិតនៅក្រុមហ៊ុន **សៀខ ហៃរី ហ្សេត** ខូអិលធីឌី ៕


ក្រុមការងារកំណត់អត្តសញ្ញាណកម្មករនិយោជិតនៅខេត្តស្វាយរៀង

## សកម្មភាពក្រុមការងារចុះកំណត់អត្តសញ្ញាណ នៅខេត្តព្រះវិហារ

**ព្រះវិហារ៖** ថ្ងៃព្រហស្បតិ៍ ០៦កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សាខាខេត្តព្រះវិហារ បានចុះទៅកំណត់អត្តសញ្ញាណកម្មករនិយោជិត ដែលបម្រើការងារនៅសណ្ឋាគារព្រះវិហារពេជ្រ ផ្ទះសំណាក់សុខ សាន្ត និងខារ៉ាអូខេ រស្មីពេជ្រ។


ក្រុមការងារកំណត់អត្តសញ្ញាណកម្មករនិយោជិតនៅខេត្តព្រះវិហារ

គោលបំណងនៃការចុះកំណត់អត្តសញ្ញាណនេះ គឺដើម្បីឱ្យកម្មករនិយោជិតទទួលបានអត្ថប្រយោជន៍ផ្សេងៗ ពី ប.ស.ស និងអាចឱ្យពួកគាត់មានសិទ្ធិទៅទទួលបានសេវាពិនិត្យ និងព្យាបាលជំងឺនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ (មន្ទីរពេទ្យរដ្ឋ) និងអត្ថប្រយោជន៍ផ្សេងៗដែល ប.ស.ស បានផ្តល់ជូន៕

# ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ ចុះអង្កេតករណីសន្លប់នៅខេត្តកំពង់ស្ពឺ




កម្មករនិយោជិតដែលសន្លប់ កំពុងទទួលសេវាសម្រាក និងព្យាបាល ពីបេឡាជាតិរបបសន្តិសុខសង្គម

កំពង់ស្ពឺ៖ ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ (ទ.ស.ប.ក) បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃចន្ទ ២រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ បានចុះធ្វើការសម្របសម្រួល និងអង្កេតករណីកម្មករនិយោជិតដួលសន្លប់ចំនួន ៣៤នាក់ នៅរោងចក្រផលិតស្បែកជើងឈ្មោះញូ អេធីធី ស៊ូ មេឃីង (New ATT Shoes Making) ស្ថិតនៅផ្លូវជាតិលេខ០៤ ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ ក្រោយពីការជួបប្រជុំពិភាក្សាជាមួយមន្ត្រី និងបុគ្គលិកនៃ សាខា ប.ស.ស ខេត្ត រដ្ឋបាលរោងចក្រ តំណាងនិយោជិត ប្រធាន អនុប្រធានសហជីព ព្រមទាំងធ្វើការត្រួតពិនិត្យវាស់ស្ទង់កម្រិតសីតុណ្ហភាពទាំងក្នុង និងក្រៅរោងចក្រ ។

ក្រុមការងារ ទ.ស.ប.ក បានសង្កេតឃើញថា កម្មករនិយោជិតដែលបានសន្លប់ក្នុងករណីខាងលើនេះ បណ្តាលមកពីបញ្ហាសុខភាព។ រាល់ថ្លៃសេវាដឹក ជញ្ជូន និងសេវាព្យាបាលរហូតដល់ជាសះស្បើយគឺជាបន្ទុករបស់ ប.ស.ស៕



ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ (ទ.ស.ប.ក) ចុះអង្កេតក្នុងករណីសន្លប់

# បុគ្គលិកគ្រឹះស្ថានប្រាសាក់ម្នាក់ទទួលបានថ្លៃសេវាព្យាបាលពី បេឡាជាតិរបបសន្តិសុខសង្គម

**ត្បូងឃ្មុំ៖** នៅវេលាម៉ោងប្រមាណ ០៦ និង ០០នាទី ព្រឹកនៅថ្ងៃចន្ទ ៣កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ មានករណីគ្រោះថ្នាក់ការងារមួយបានកើតឡើងស្ថិតនៅភូមិស្លាបក្តោង ឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ បណ្តាលឱ្យជនរងគ្រោះឈ្មោះ **ឡេង ពិសី** ភេទស្រី អាយុ **២៤ឆ្នាំ** បម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ រងរបួសធ្ងន់ត្រង់ក្បាល និងរលាត់ផ្ទៃមុខ។ ហេតុការណ៍ គ្រោះថ្នាក់ខាងលើបណ្តាលមកពីជនរងគ្រោះជិះម៉ូតូធ្លាក់ជង្ហុកបោកក្បាលទៅនឹងថ្មល់កៅស៊ូ។ ភ្លាមៗនោះ មន្ត្រី និងក្រុមការងារនៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សហការ ជាមួយអាជ្ញាធរមូលដ្ឋានចុះទៅត្រួតពិនិត្យសម្របសម្រួល បញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យខេត្តកំពង់ចាម។



រូបភាពកម្មការិនីដែលរងគ្រោះថ្នាក់ការងារ

ដោយសារករណីគ្រោះថ្នាក់ខាងលើជាគ្រោះថ្នាក់ការងារ រាល់ថ្លៃសេវាដឹកជញ្ជូន និងសេវាព្យាបាលរហូតជាសះស្បើយជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម៕

# ប.ស.ស ចេញថ្លៃសេវាព្យាបាលរហូតជាសះស្បើយលើកម្មករ កម្មការិនី ៦៣ នាក់

**ព្រះសីហនុ៖** នៅថ្ងៃអង្គារ ៥រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨ មានគ្រោះថ្នាក់ចរាចរណ៍មួយបានកើតឡើង បណ្តាលឱ្យកម្មករនិយោជិតចំនួន **៦៣នាក់** រងរបួសធ្ងន់ និងស្រាល ក្នុងហេតុការណ៍នេះមានកម្មករ កម្មការិនី **៤៨នាក់** និងស្ត្រីមានផ្ទៃពោះចំនួន **០៦នាក់**។

ហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ខាងលើបណ្តាលមកពីរថយន្តដឹកទឹកកក បម្រុងបើកវ៉ាជែងរថយន្តដឹកកម្មករ ប៉ុន្តែពេលឃើញឧបសគ្គមកពីខាងមុខរថយន្តដឹកទឹកកកក៏បានគេចចូលមកវិញហើយក៏បុករថយន្តដឹកកម្មករ **០១គ្រឿង** និងបន្តបុករថយន្តដឹកកម្មករផ្សេងជាបន្តបន្ទាប់ ។ ហេតុ-ការណ៍ នេះស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៤ ក្នុងភូមិ-ពូធឿង ឃុំបិតត្រាង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម សាខាខេត្តព្រះសីហនុ សហការជាមួយសមត្ថកិច្ចក្នុងមូលដ្ឋានចុះទៅសម្របសម្រួល និងបានបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យបង្អែកនៅ ខេត្តព្រះសីហនុ ចំនួន **១៦នាក់** **(ស្រី១៣នាក់)**



រូបភាពកម្មករនិយោជិតដែលរងគ្រោះថ្នាក់ការងារ

គ្លីនិកសេតេ ចំនួន **៣៣នាក់** គ្លីនិក វណ្ណី ចំនួន **១២នាក់** គ្លីនិកចាក់អង្រែ ចំនួន **០១នាក់** បន្ទប់ពិគ្រោះជំងឺ **០១នាក់** កម្មករឈ្មោះ គី យ៉ា ដេត និង កម្មករឈ្មោះ យ៉ន លៃ ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ កាល់ម៉ែត។ រាល់សេវាដឹកជញ្ជូន និងព្យាបាលជំងឺរហូតដល់ ជាសះស្បើយជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម៕

# ប.ស.ស បានផ្តល់ប្រាក់វិភាជន៍បូជាសព ដល់កម្មការិនីម្នាក់ដែលបានស្លាប់ដោយខ្យល់គរនៅខេត្តស្វាយរៀង

**ស្វាយរៀង៖** នៅថ្ងៃព្រហស្បតិ៍ ១៣កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សាខាខេត្តស្វាយរៀង បានចុះអង្កេតគ្រោះថ្នាក់ដែលបណ្តាលឱ្យកម្មការិនីម្នាក់បានស្លាប់ នៅខណៈពេលកំពុងឈររង់ចាំឡានដឹកកម្មករត្រឡប់ទៅផ្ទះវិញ។






សូមបញ្ជាក់ផងដែរថាករណីនេះ បានកើតឡើងកាលពីល្ងាចថ្ងៃពុធ ទី២៨ ខែមីនា ឆ្នាំ២០១៨ ស្ថិតនៅភូមិជ្រៃធំ សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង ជនរងគ្រោះឈ្មោះ **ដាំ ណាយ** ភេទស្រី បម្រើការងារនៅរោងចក្រ ស័ងលី (ខេមបូឌា) ហ្គាមេន ខូអិលធីឌី SHAUNG LI (Cambodia) Garment Co. Ltd ។

បន្ទាប់ពីក្រុមការងារបានចុះអង្កេតរួចមកបានឱ្យដឹងថា ករណីគ្រោះថ្នាក់ខាងលើ គឺជាករណីគ្រោះថ្នាក់ការងារ ដូចនេះមន្ត្រីបេឡាជាតិរបបសន្តិសុខសង្គមបានសម្របសម្រួល រៀបចំឯកសារនឹងផ្តល់ប្រាក់វិភាជន៍បូជាសពចំនួន ៤ ០០០ ០០០រៀល ដល់ក្រុមគ្រួសារសព ព្រមទាំងអត្ថប្រយោជន៍ពី ប.ស.ស ផ្សេងៗទៀត៕





# នីតិវិធី ដើម្បីទទួលបានបណ្ណសមាជិក ប.ស.ស




# តើអ្នកណាខ្លះដែលអាចប្រើប្រាស់បណ្ណសមាជិក ប.ស.ស បាន ?



# បណ្ណសមាជិក ប.ស.ស និង បណ្ណមូលនិធិសមធម៌សុខាភិបាល




# ធនាគារដែលនិយោជកអាចបង់ភាគទានមកកាន់ ប.ស.ស



# សម្តេចព្រះមហាសុមេធាធិបតី ជួន ណាត (ជោតញ្ញាណោ)
# សម្តេចព្រះសង្ឃរាជថ្នាក់ទី១ នៃគណៈមហានិកាយ
# ប្រសូត ១១ មីនា ព.ស.២៤២៧/គ.ស.១៨៨៣
# សុគត ២៥ កញ្ញា ព.ស.២៥១៣/គ.ស.១៩៦៩

សុភាសិតសម្តេចជាអម្ចាស់៖

១. ការអម្បាល កុំអាលពោលអួតមុន ។
២. ឧបាយកលសើៗ ពុំស្មើគំនិតជ្រៅ ។
៣. កំណាចឃ្លានពេក មានរឿងពុំសូវស្រាក ។
៤. សេពគប់ពាល ពាលនាំទៅរកខុស សេពគប់ប្រាជ្ញប្រុស ប្រាជ្ញនាំទៅរកត្រូវ ។
៥. សូវនូវម្នាក់ឯង គួរជៀសវាងបាបមិត្ត ។
៦. ចិត្តឥតភ្នែក ភ្នែកឥតចិត្ត អ្នកគិតល្អិតទើបអាចយល់បាន ។
៧. មើលងាយអ្នកផង នាំឲ្យកន្លងច្បាប់ ។
៨. រអិលមាត់ច្រើនតែភ្លាត់ស្នៀត ។
៩. សើចក្អាកក្អាយ នាំឲ្យស្តាយក្រោយ ។
១០. កាប់បំពង់រង់ចាំទឹកភ្លៀង ភ្នែកមិនឆ្មៀងឃើញមិនសព្វ ។
១១. ធ្វើស្រែទាន់មានភ្លៀង ស្រែកច្រៀងទាន់មានភ្លេង ។
១២. ពេលត្រូវដើរបែរជាដេក ខ្ជិលហួសពេកនាំឲ្យល្ងង់ ។
១៣. មានៈចចេសក្រៃ អស់តម្លៃគ្មានចំណេញ ។
១៤. បំណាច់កើតជាអង្គប្រុស កុំប្រព្រឹត្តខុសធម៌ច្បាប់ ។
១៥. ប្រាំបួនទិញ ដប់ទិញ កុំទិញរបស់ចោក ។
១៦. កុំស្តាយគុម្ពចេកមួយគុម្ព ។
១៧. កុំស្តាយអាចម៍គោមួយគំនរ ។
១៨. បើមិនចេះត្រូវសួរគេ កុំមានៈយកគ្រាន់បើ ។

សុភាសិតទាំងអស់នេះ ព្រះអង្គតែងមានព្រះបន្ទូលទៅកាន់ពួកយុវជនជារឿយៗ ដើម្បីឲ្យបានទៅជាពលរដ្ឋមួយរូបថ្លៃថ្នូរនឹងគេ កុំឲ្យក្រាញនៅតែមួយកន្លែង ត្រូវតែផ្លាស់ដីថ្មី គំនិតថ្មី ទើបរកសុភមង្គលឃើញ មិនគួរគប្បីស្តាយស្រណោះដីកំហិល ដែលមានតែដើមត្នោតឬចេកដូងមួយគុម្ពពីរឡើយ ។ល។

ដកស្រង់ពីសៀវភៅទស្សនៈសម្តេចសង្ឃរាជ ជួន ណាត

ចម្លងដោយលោក គង់ សម្ភារ (១៩៧០) ។

# រាជរដ្ឋាភិបាល សម្រេច ដាក់ឱ្យប្រើប្រាស់ ក្រដាសប្រាក់ ២០ ០០០រៀល គំរូប្រភេទថ្មី






ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦២ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**
**ការចេញផ្សាយធនប័ត្រ ប្រភេទ ២០០០០ រៀល គំរូថ្មី**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- តាមសំណើរបស់អគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា

**សម្រេច**

**មាត្រា១.-** អនុញ្ញាតឱ្យចេញផ្សាយ ធ្វើចរាចរ និងប្រើប្រាស់ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា នូវធនប័ត្រប្រភេទ ២០០០០ រៀល គំរូថ្មី ទន្ទឹមនឹងបណ្តាប្រភេទប្រាក់ដែលត្រូវបានចេញផ្សាយរួចហើយ ។

**មាត្រា២.-** ធនាគារជាតិនៃកម្ពុជាមានភារកិច្ចចេញសេចក្តីប្រកាស ដើម្បីផ្សព្វផ្សាយពីលក្ខណៈសម្គាល់នៃធនប័ត្រប្រភេទ ២០០០០ រៀល គំរូថ្មីនេះ ។

**មាត្រា៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន និងអភិបាលរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ... ខែ... ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

តាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ បានបញ្ជាក់ថា៖ អនុញ្ញាតឱ្យចេញផ្សាយធ្វើចរាចរ និងប្រើប្រាស់ទូទាំងព្រះរាជាណាចក្រកម្ពុជា នូវធនប័ត្រប្រភេទ២០ ០០០រៀលគំរូថ្មី។

ធនាគារជាតិនៃកម្ពុជា មានភារកិច្ចចេញសេចក្តីប្រកាស ដើម្បីផ្សព្វផ្សាយអំពីលក្ខណៈសម្គាល់ នៃធនប័ត្រប្រភេទ ២០ ០០០រៀលគំរូថ្មី។ ដោយឡែកតាមសេចក្តីប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ចុះហត្ថលេខាដោយ **ឯកឧត្តម ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ បានឱ្យដឹងថា ដោយអនុលោមតាមអនុក្រឹត្យលេខ ៦២ អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការចេញផ្សាយនូវធនប័ត្រប្រភេទ ២០ ០០០រៀល គំរូថ្មីក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជា សូមប្រកាសផ្សាយជាសាធារណៈ ។

# វិធីសាស្ត្រងាយៗ កំចាត់ផ្ដាសាយ

អាកាសធាតុប្រែប្រួល បានធ្វើឱ្យយើងជួបនឹងបញ្ហាផ្ដាសាយជាញឹកញាប់។ ប៉ុន្តែពេលនេះ លោកអ្នកប្រាកដជាអស់កង្វល់ទៀតហើយ ឱសថធម្មជាតិដែលមានស្រាប់ក្នុងផ្ទះទាំងនេះ អាចជួយបង្កើនល្បឿននៃការជាសះស្បើយឡើងវិញបានយ៉ាងឆាប់រហ័ស ៖

**១. ទឹកឃ្មុំ និងក្រូចឆ្មារ**

ទឹកឃ្មុំ និងក្រូចឆ្មារ ជួយសម្រួលដល់បំពង់ក និងធ្វើឱ្យលោកអ្នកគេងលក់បានស្រួល។ ក្រូចឆ្មារបានបន្ថែមវីតាមីនដែលត្រូវការចាំបាច់ ហើយវាក៏អាចជួយសំអាត មេរោគពីច្រមុះបានយ៉ាងល្អផងដែរ។



**២. ខ្ទឹមស**

ខ្ទឹមសមានកេរ្តិ៍ឈ្មោះយូរអង្វែង ដែលត្រូវបានគេប្រើសម្រាប់ថែរក្សាពូជសត្វផ្សេងៗក្នុងរដូវរងា។ ឥឡូវនេះយើងបានផ្លាស់ប្ដូរពីរបៀបប្រើប្រាស់ ដោយអាចបន្ថែមខ្ទឹមសក្នុងអាហាររបស់យើងបានយ៉ាងងាយស្រួល និងថែមទាំងសម្រាប់ទទួលទានអាហារបំប៉នប្រចាំថ្ងៃ។ ខ្ទឹមសអាចប្រឆាំងនឹងបាក់តេរី ប្រឆាំងនឹង Catarrhal ដែល ជាអាវុធដ៏អស្ចារ្យមួយប្រឆាំងនឹងជំងឺផ្ដាសាយ។



**៣. វីតាមីន D**

អ្នកគួរក្រោកពីព្រលឹមហាត់ប្រាណ ឬធ្វើយ៉ាងណាឱ្យរាងកាយរបស់អ្នក បាន ប៉ះផ្ទាល់ជាមួយ កាំរស្មីដ៏ស្រទន់របស់ព្រះអាទិត្យ ។ ហេតុផលសំខាន់ គឺវីតាមីនD ដែលជួយការពារជំងឺគ្រុនផ្ដាសាយ និងអាចគ្រប់គ្រងការឆ្លើយតបនៃប្រព័ន្ធភាពស៊ាំរបស់យើង។ ចំពោះការប៉ះទៅនឹងកាំរស្មី UVB របស់ព្រះអាទិត្យឱ្យបាន គ្រប់គ្រាន់អ្នក ត្រូវការ ពេល វេលាយ៉ាង តិច ១៥ នាទីក្នុង មួយថ្ងៃ។ វាជួយបង្កើនប្រព័ន្ធភាពស៊ាំជំនួយឆ្អឹងសន្លាក់ និងសុខភាពបេះដូង៕



អត្ថបទដកស្រង់: http://www.khmerscoop.com

# តើមានអ្វីកើតឡើងខ្លះក្រោយពីអ្នកឈប់ផឹកស្រារយៈពេល២១ថ្ងៃ?

ខាងក្រោមនេះ គឺជាការផ្លាស់ប្ដូរ និងសារៈប្រយោជន៍មួយចំនួនចំពោះសុខភាព ក្រោយពេលអ្នកឈប់ផឹកស្រា ត្រឹមតែ ២១ ថ្ងៃដំបូងតែប៉ុណ្ណោះ។

១. សម្រកទម្ងន់ និងកាត់បន្ថយជាតិខ្លាញ់អាក្រក់
២. ស្បែករបស់អ្នកនឹងស្រស់ថ្លា និងស្រស់ស្អាតជាងមុន
៣. កម្រិតកូឡេស្តេរ៉ូលអាក្រក់ថយចុះជាលំដាប់
៤. ការពារជំងឺទឹកនោមផ្អែម
៥. ខួរក្បាលនឹងមានសុខភាពល្អជាងមុន ហើយចងចាំបានល្អប្រសើរ
៦. សាច់ដុំមាំមួន
៧. ប្រព័ន្ធភាពស៊ាំរឹងមាំ៕

អត្ថបទដកស្រង់: http://www.khmerscoop.com

# កំណាព្យ

## ក្រមា១ពាន់ម៉ែត្រ បានព្រោះហេតុខ្មែររួមគ្នា



បទៈ ព្រហ្មគីតិ

GoGo Cambodia
មករួមគ្នាកុំអល់អែក
កុំមើលហើយចាំស្រែក
រួមបំបែកកំណត់ត្រា។

អំបោះកីតម្បាញ
ត្រល់បង្ហាញយ៉ាងសង្ហា
ត្រៀមរួមត្បាញក្រមា
ឱ្យអស្ចារ្យល្បីខ្ចរខ្ចារ។

ក្រមា១ពាន់ម៉ែត្រ
បានព្រោះហេតុខ្មែររួមគ្នា
ពុកម៉ែអ៊ុំមីងមា
ទោះបីជាពិការក្តី។

ពិសេសយុវជន
ដែលជាធនកម្លាំងថ្មី
រួមត្បាញទាំងប្រុសស្រី
មិនចេះក្តីអាចរៀនបាន។

រួមរក្សវប្បធម៌
បើកទំព័រឱ្យល្បីថ្កាន
ប្រាប់ថាខ្មែរធ្វើបាន
ពេលស្រុកក្សាន្តលែងច្បាំងគ្នា។

អំបោះមួយសរសៃ
រួមគ្រប់ដៃពិតបានជា
ក្រមាវែងរួមគ្នា Cambodia
កាន់តែល្បី។

អត្ថបទដកស្រង់: thmeythmey.com/?page=detail&id=60877

# ទំនាក់ទំនងតាមរយៈ


អាស័យដ្ឋានៈ អាគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទៈ (០២៣) ៨៨១ ១៣៩, ៨៨០ ៩១៥, ៨៨១ ០១៦, ៨៨១ ១៧៦, ៨៨១ ០១៥
(០២៣) ៨៨១ ១៩៩, ៨៨២ ៦២៣, ៨៨២ ៩៣៩, ៨៨០ ៦១៩, ៨៨០ ៩១៧

គេហទំព័រៈ www.nssf.gov.kh

អ៊ីម៉ែលៈ info@nssf.gov.kh